មជ្ឈមណ្ឌលឯកសារកម្ពុជា

# របាយការណ៍
# ស្តីពីទីតាំងប្រល័យពូជសាសន៍ខេត្តកំពង់ឆ្នាំង
# កាលពីថ្ងៃទី១០-១៥ ខែមិថុនា ឆ្នាំ២០០២

ដោយៈ ផេង ពង្សរ៉ាស៊ី

ការធ្វើដំណើរទៅកាន់ខេត្តកំពង់ឆ្នាំងបានប្រព្រឹត្តិទៅកាលពីថ្ងៃចន្ទ័ទី១០ ខែមិថុនា ឆ្នាំ២០០២ វេលាម៉ោង៧និង៣០នាទីព្រឹកតាមបណ្តោយផ្លូវជាតិលេខ៥ ។ ការធ្វើដំណើរនេះបានចំណាយពេលអស់ជិត៣ម៉ោងពីព្រោះកំណាត់ផ្លូវត្រូវជួសជុលដោយកន្លែង និងចរាចរណ៍ត្រូវកកស្ទះ ។ ម៉ោងប្រមាណជាង១០ព្រឹក ក្រុមស្រាវជ្រាវធ្វើផែនទីរណ្តៅបានទៅដល់សាលាខេត្តកំពង់ឆ្នាំង ។ នាពេលបន្ទាប់ ខ្ញុំបានធ្វើដំណើរបន្តឆ្ពោះទៅកាន់សាលាស្រុករលាប្អៀរ ។ ក្រោយពីមានការអន្តរាគមន៍ចំពោះកិច្ចការស្រាវជ្រាវរួចមក ខ្ញុំបានធ្វើដំណើរបន្តទៅកាន់ឃុំអណ្តូងស្នាយ ។

## ១) ស្រុករលាប្អៀរ

*អូរបុស្សី (ទីតាំងសម្លាប់ និងមន្ទីរសន្តិសុខ)*

*លេខកូតភូមិសាស្ត្រ ០៤០៦០៩*

*រយៈកំពស់* **(N) 12º 08'57:96"**

*រយៈទទឹង* **(E) 104º 41'41:23"**

ឃុំអណ្តូងស្នាយ មានទីតាំងមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មួយកន្លែងឈ្មោះថា អូបុស្សី ដែលស្ថិតក្នុងភូមិកំពង់ផ្ទឹក ។ ខ្លោងទ្វារវត្តត្រពាំងទឹកត្រជាក់ គឺជាគោលដៅតែមួយគត់សម្រាប់ការធ្វើដំណើរទៅកាន់ទីតាំងអូបុស្សី ។ ក្នុងចម្ងាយដីប្រហែលបីគីឡូម៉ែត្រខ្ញុំបានធ្វើដំណើរទៅដល់ផ្ទះប្រាក់ យន័ ដែលរស់នៅក្នុងភូមិកំពង់ ផ្ទឹក ឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ។ យន័ បាននិយាយប្រាប់ពីទីតាំងសម្លាប់នៅអូរបុស្សីថាៈ

អូរបុស្ស៊ី គឺជាទីតាំងសម្លាប់ និងជាមន្ទីរអប់រំកែប្រែ(ជាមន្ទីរកសាង)របស់ខ្មែរក្រហមកាលពីអំឡុងឆ្នាំ១៩៧៥-៧៦ ។ ជនរងគ្រោះភាគច្រើនគឺជាអ្នកដែលជាប់និន្នាការពីសង្គមចាស់ដូចជាទាហាន និងមន្ត្រីរាជការផ្សេងៗទៀត ។ មានភាគតិចបំផុតជាអ្នកមូលដ្ឋាន ។ កំហុសនៃអ្នកមូលដ្ឋានទាំងនោះ គឺដោយសារមានជាប់ពាក់ពន្ធ័នឹងការលួចនេះលួចនោះ, អ្នកខុសសីលធម៌ និងអ្នកដែលខ្ជិលច្រអូសក្នុងការបំពេញការងារ ។ ពុំមានការ

បំផ្លាញវត្តអារ៉ាម ប្តូរ៉ឹកព្រះសង្ឃឡើយនៅក្នុងឃុំអណ្តូងស្នាយ ។ ក្រុមកងឈ្លបក្មេងៗ (អាយុមិនដល់២០ឆ្នាំ) បានណែនាំខ្លួនចំពោះប្រជាជន ទូទៅថាខ្លួនជាមនុស្សខ្លាំងដែលបានអនុវត្តតាមបញ្ជាបានល្អឥតខ្ចោះ ។ ពួកគេ(កងឈ្លប) ជាអ្នកដែលត្រួត ត្រាលើប្រជាជន និងជាអ្នកចាប់ប្រជាជនមកដាក់ក្នុងមន្ទីរអប់រំអូរបុស្សីប្រសិនបើអ្នកទាំងនោះ(ប្រជាជន) បានប្រព្រឹត្តិខុស ។ ហេតុការណ៍ជាច្រើនដូចជាការនាំអ្នកទោសចូលក្នុងមន្ទីរអប់រំ ឬមន្ទីរកសាង បានត្រូវ យន៍ ដឹងទាំងអស់ ព្រោះគាត់កំពុងមានការងារធ្វើនៅក្បែរៗនោះ ។ មនុស្សជាច្រើនត្រូវបាន យ៉ន ស្គាល់ច្បាស់ថាមិនមែនជាមនុស្សដែលរស់នៅក្នុងភូមិ-ឃុំរបស់គាត់នោះ បានត្រូវបណ្តើរទាំងខ្សែៗចូលក្នុងមន្ទីរកសាងទាំងអស់ ។

សឿ ទ្រឿង អាយុ៦៧ឆ្នាំជាជាងអាឈើដែលរស់នៅក្នុងភូមិកណ្តាល ឃុំអណ្តូងស្នាយ បានប្រាប់ថាប្រជាជនដែលបាននាំចូលក្នុងមន្ទីរអប់រំដោយកងឈ្លបខ្មែរក្រហម គឺជាប្រជាជនដែលបានជម្លៀសមកពីខេត្តកណ្តាល និងខេត្តកំពង់ស្ពឺ ។ ទ្រឿង បានដឹងយ៉ាងប្រាកដថាប្រជាជនទាំងនោះគឺជាប្រជាជនសាមញ្ញមិនមែនជាអ្នកដែលមានជាប់ទាក់ទិននឹងនិន្នាការនយោបាយដូចដែលខ្មែរក្រហមចោទប្រកាន់នោះទេ ។ អ្នកទោសនៅមន្ទីរអប់រំអូរបុស្សីទាំងអស់បានត្រូវទទួលបញ្ជាឲ្យធ្វើការទាំងព្រឹកទាំងល្ងាចនៅក្នុងវង្ស់នៃមន្ទីរអប់រំតែម្តង ។ ការងាររបស់ពួកគេគឺដាំដើមដូង និងកាប់ដីដីបូក ។ ប្រាក់ យ៉ន បានបង្ហាញពីសំណល់ភស្តុតាងនៅកន្លែងកើតហេតុនូវរណ្តៅដែលបានកាប់ដាំដើមដូងនិងដីដីបូកដែលបានកាប់រំលោយកាលពីជំនាន់នោះ(ខ្មែរក្រហម) ។ ការប្រជុំបានធ្វើឡើងជារៀងរាល់ព្រឹកមុនពេលទៅធ្វើការ និងរាល់ល្ងាចពេលដែលត្រឡប់មកពីធ្វើការវិញ ។ ផែនការនៃការប្រជុំនោះគឺដើម្បីពង្រឹងគោលជំហរបដិវត្តន៍ និងការងារ ។ ចំណែកឯការសួរចម្លើយនិងធ្វើទារុណកម្មវិញក៏មានកើតឡើងជារៀងរាល់ថ្ងៃដែរគឺនៅពេលដែលអ្នកទោសថ្មីបានត្រូវបញ្ជូនមក ។ គោលបំណងសំខាន់នៃការសួរចម្លើយគឺគ្មានអ្វីក្រៅពីចង់បានចម្លើយប្រាប់ថាបានធ្វើក្បត់នឹងអង្គការពិតមែន ។ អ្នកទោសធ្ងន់ត្រូវជាប់ច្រវ៉ាក់ជើងទាំងសន្ធាង ហើយត្រូវបណ្តើរឲ្យចេញមកធ្វើការខាងក្រៅនាពេលថ្ងៃ ហើយបញ្ចូលក្នុកមន្ទីរវិញនៅពេលល្ងាច ។ កងការពារមន្ទីរប្រមាណ៤-៥នាក់ បានដាក់គ្នាពង្រាយក្នុងព្រៃស្បាតនៅពេលដែលបញ្ចេញអ្នកទោសឲ្យមកធ្វើការ ។ រាល់ពេលទៅបំពេញភារកិច្ចរបស់កងឈ្លបខ្មែរក្រហម ពួកគេតែងតែលីកាំបិតជាប់នឹងស្មាជានិច្ចជាមួយនឹងឯកសណ្ឋានជាកម្មាភិបាលខ្មែរក្រហម ។

ការសម្លាប់មនុស្សនៅមន្ទីរអូរបុស្សី បានកើតឡើងព្រមគ្នាជាមួយនឹងការសម្លាប់មនុស្សនៅខ្សាចសរ (ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើការស្រាវជ្រាវម្តងរួចហើយនៅឆ្នាំ១៩៩៨) ដែលមានចម្ងាយពីគ្នាតែប្រមាណ១គីឡូម៉ែត្រប៉ុណ្ណោះ ។ វាលពិឃាតនៅខ្សាច់សរបានសម្លាប់មនុស្សអស់រាប់ម៉ឺននាក់ ។

*ចំណែកឯនៅមន្ទីរអូរបុស្សីវិញ ក៏មិនតិចជាង១០០០នាក់ដែរនៃមនុស្សដែលបានសម្លាប់កាលពីឆ្នាំ១៩៧៥-៧៦ ។រណ្តៅបានត្រូវជីកឡើងរួចជាស្រេចដោយកងការពារមន្ទីរដែលរណ្តៅមួយៗទំហំទទឹង៥ម៉ែត្របណ្តោយ១០ម៉ែត្រ និងជម្រៅ១ម៉ែត្រ និងមានរណ្តៅខ្លះទៀតមានទំហំលើសពីនេះ ។ ប្រាក់ យន់ បានអធិប្បាយពីការនាំយកមនុស្សទៅសម្លាប់ថាខ្លួនបានឃើញផ្ទាល់នឹងភ្នែក នូវការបណ្តើរមនុស្សចេញពីមន្ទីរនាពេលព្រលប់ៗ យកទៅកាន់រណ្តៅនៅពេលដែលគាត់ចូលទៅយកស្រាតាមបញ្ជាប្រធានកង ។ ការសម្លាប់មនុស្សបានប្រព្រឹត្តិឡើងនៅពេលយប់ ។ ជួនកាល យន់ បានប្រទះឃើញដីដែលកប់សាកសពនោះហាក់មានចលនាកម្រើក ឡើង ។ មានអ្នកទោសប្រហែលជាង២០០នាក់បានត្រូវបណ្តើរយកទៅសម្លាប់នៅទីតាំងអូរបុស្សីដែរ ។ តាមការរាយការណ៍ពី ប្រាក់ យន់ថា បានបណ្តើរមកពីកន្លែងផ្សេងក្រៅពីមន្ទីរអប់រំកែប្រែអូរបុស្សី ។*

*មានរណ្តៅរហូតដល់ទៅជាង១០០រណ្តៅ និងសាកសពរាប់ពាន់នាក់បានស្លាប់នៅក្នុងរណ្តៅទាំងនោះ ។*

*ក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ រណ្តៅទាំងប៉ុន្មានបានបន្សល់ទុកនូវភាពក្រហេងក្រហូងដូចរន្ធបាយខុម ។ សំណល់មន្ទីរឃុំឃាំងនិងមន្ទីរធ្វើការរបស់កងការពារទាំងប៉ុន្មានបានត្រូវរុះរើទាំងអស់ ។ អ្នកកាន់កាប់មន្ទីរនេះបានត្រូវសម្លាប់ស្ទើរអស់នៅក្នុងសង្គ្រាម ។ អ្នកទោសមួយចំនួនដែលមិនទាន់បានសម្លាប់ ត្រូវរត់យ៉ាងប្រសេកប្រសាចចេញពីមន្ទីរឃុំឃាំងនេះ ។ ទោះជាយ៉ាងនេះក៏ដោយក៏អ្នកទោសដែលនៅសេសសល់នេះនៅមានចំនួនតិចបំផុត ។ ខ្ញុំបានខំស៊ុះស្វែងរកអ្នកទោសដែលនៅសេសសល់ទាំងនោះ ប៉ុន្តែជាការអត់ប្រយោជន៍ ព្រោះរកមិនបានសោះដោយសារតែអ្នកទាំងនោះមិនមានស្រុកកំណើតនៅកំពង់ឆ្នាំង ។ ក្មួយស្រីតូចៗពីរនាក់រួមនឹងបងបង្កើតម្នាក់របស់ប្រាក់ យន់ បានត្រូវបាត់ខ្លួនរហូតបន្ទាប់ពីបានត្រូវចាប់ខ្លួនកាលពីឆ្នាំ១៩៧៦មក ។ យន់ បានសន្និដ្ឋានថា ពួកគាត់បានស្លាប់អស់ទៅហើយនៅក្នុងមន្ទីរអូរបុស្សីនេះ ។*

*បច្ចុប្បន្នមន្ទីរនេះបានក្លាយជាតំបន់ព្រៃរបោះដែលស្ថិតនៅឆ្ងាយរាប់គីឡូម៉ែត្រពីភូមិអ្នកស្រុក ។ មានតែផ្លូវរទេះខ្វាត់ខ្វែងប៉ុណ្ណោះដែលបានធ្វើចរាចរណ៍កាត់តាមតំបន់អតីតមន្ទីរឃុំឃាំងអូរបុស្សីនោះ ប៉ុន្តែមិនដែលមានមនុស្សដើរកាត់ដោយគ្មានគ្នាទៅជាមួយបានទេ ។*

*ចំបក់កោង (ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខ)*

*លេខកូតភូមិសាស្ត្រ ០៨០៦១០*

*រយៈកំពស់* **(N) 12º 06'56:11"**

*រយៈទទឹង* **(E) 104º 43'12:26"**

ចំបក់កោង ស្ថិតនៅក្នុងភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។

ចំបក់កោងជាឈ្មោះមួយដែលប្រជាជនរស់នៅម្តុំនោះនិយមហៅគ្រប់ៗគ្នា ព្រោះទីតាំងនោះមានដើមចំបក់មួយដែលមានលក្ខណៈខុសពីដើមចំបក់ដទៃទៀត ។ រហូតមកដល់បច្ចុប្បន្នដើមចំបក់នោះនៅតែមានរូបរាងចម្លែកពីគេដដែល ។ កាលពីជំនាន់ដែលគ្រប់គ្រងដោយខ្មែរក្រហម ទីនោះ(ចំបក់កោង) បានត្រូវជ្រើសរើសធ្វើជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន និងកន្លែងធ្វើទណ្ឌកម្មយកចម្លើយ និងទីបញ្ចប់ជាកន្លែងសម្លាប់មនុស្ស ។ សុខ ជាតិ អាយុ៧៦ឆ្នាំ រស់នៅភូមិត្រពាំងក្រពើ ឃុំទឹកហូត ស្រុករលាប្អៀរបាននិយាយថា ចំបក់កោងគឺជាកន្លែងសម្លាប់មនុស្សដែលខ្មែរក្រហមបានយកមកផ្ញើតាមសហករណ៍នានាក្នុងឃុំទឹកហូត ។ ប្រជាជនមូលដ្ឋានមួយចំនួនក៏បានសម្លាប់ចោលដែរ ព្រោះតែមានកំហុសបន្តិចបន្តួចជាមួយសហករណ៍ ។ ការសម្លាប់មនុស្សនៅនឹងទីតាំងចំបក់កោងនេះ បានប្រព្រឹត្តិទៅតាំងពីឆ្នាំ១៩៧៦មកម្ល៉េះ ប៉ុន្តែមិនទាន់មានការសម្លាប់ច្រើននៅឡើយទេ ។ លុះមកដល់ឆ្នាំ១៩៧៨ ការសម្លាប់នេះបានកើនឡើង ។ រឿងរ៉ាវនៃការសម្លាប់មនុស្សអស់យ៉ាងច្រើននៅទឹកដីឃុំទឹកហូតនេះ ត្រូវបានប្រជាជនភាគច្រើននៅក្នុងឃុំ ស្តីបន្ទោសទៅលើការផ្លាស់ប្តូរអ្នកគ្រប់គ្រង ។ កម្មាភិបាលខ្មែរក្រហមមួយចំនួនដែលពីមុនធ្លាប់បានបម្រើបដិវត្តន៍យ៉ាងអស់ពីកម្លាំងកាយចិត្តបានត្រូវយកមកសម្លាប់ ដោយខ្មែរក្រហមដូចគ្នាដែលទើបតែផ្លាស់ចូលមក ព្រោះតែកំហុសបន្តិចបន្តួច ។ ម៉ៅ ស៊ិត អាយុ៦៤ឆ្នាំ សព្វថ្ងៃរស់នៅភូមិត្រពាំងក្រពើបានរៀបរាប់ថា នៅឆ្នាំ១៩៧៨គាត់បានឃើញខ្មែរក្រហមបណ្តើរមនុស្សជាច្រើននាក់ចូលមកកាន់មន្ទីរចំបក់កោង ហើយក្រោយមកដឹងថាអ្នកទោសទាំងនោះបានត្រូវសម្លាប់ចោលទាំងអស់ នៅក្នុងបរិវេណនោះដែរ ។ ស៊ិត បាននិយាយពីកម្មាភិបាលខ្មែរក្រហមម្នាក់ដែលបានចាប់ដាក់ក្នុងគុកនេះ ហើយក្រោយមកបានសម្លាប់ខ្លួនឯងប្រាប់ថា នៅថ្ងៃមួយ(មិនចាំ)ក្នុងឆ្នាំ១៩៧៨ ពេលដែលគាត់កំពុងដើរទៅការដ្ឋានធ្វើការរបស់គាត់ដែលស្ថិតនៅឆ្ងាយជាងព្រៃចំបក់កោងប្រហែល២០០ម៉ែត្រនោះ ស្រាប់តែប្រទះឃើញអតីតខ្មែរក្រហមម្នាក់ឈ្មោះ ជា បានលួចរត់ចេញពីបរិវេណព្រៃចំបក់កោងមកខាងក្រៅទាំងដៃ និងជើងជាប់ចំណង ។ ពេលនោះ ស៊ិត បានព្យាយាមរត់គេចចេញមិនឲ្យឈ្មោះ ជា នោះឃើញឡើយ ។ ប្រហែលមួយម៉ោងក្រោយមកឈ្មោះ ជា នោះបានចងកសម្លាប់ខ្លួនឯងនៅនឹងដើមឈើមួយដើមដែលស្ថិតនៅជាយព្រៃនោះ ។ មូលហេតុនៃការចងកសម្លាប់ខ្លួននេះត្រូវបាន ស៊ិត ទាញហេតុផលថាមកពី ជា ឈឺចិត្តនឹងអង្គការដែលមិនអធ្យាស្រ័យដល់ខ្លួនដែលបានធ្វើខុសបន្តិចបន្តួច ។ ជា គឺជាអតីតកម្មាភិបាលខ្មែរក្រហមកាលពីឆ្នាំ១៩៧៥-៧៦ ។ ដោយសារតែរឿងខុសសីលធម៌ជាមួយនារីដែលជាប្រជាជន១៧មេសាម្នាក់ក្នុងសហករណ៍ទើបត្រូវចាប់ខ្លួនយកទៅដាក់គុកយ៉ាងនេះ ។ នៅក្នុងគុកនៃមន្ទីរចំបក់កោង ជា បានទទួលនូវទណ្ឌកម្មយ៉ាង

សម្បើមពីកម្មាភិបាលខ្មែរក្រហមដែលទើបតែផ្លាស់ចូលថ្មីដែលមានឈ្មោះ ខាន់ ជាដើម ។ អ្នកទោសភាគច្រើនបានត្រូវដឹកជញ្ជូនយកទៅសម្លាប់នៅក្នុងទីតាំងមួយឈ្មោះថា «ព្រៃកោះ (ទីតាំងនេះមិនអាចទៅបានទេព្រោះនៅឆ្ងាយដាច់ស្រយ៉ាល និងមានសុទ្ធតែព្រៃក្រាស់ៗ)» ។ ចំណែកឯអ្នកទោសខ្លះទៀតត្រូវបានសម្លាប់នៅនឹងមន្ទីរចំបក់កោងនេះតែម្តង ព្រោះ ស៊ិត បានឃើញមានឆ្អឹង, ស្នាមឈាម និងឧបករណ៍សម្លាប់ផ្សេងទៀតដូចជាដំបង និងដងចបនៅក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ក្រៅពីនេះទៅនៅមានគុ និងកៅអីទៀតដែល ស៊ិត បានប្រាប់ថាជាកន្លែងសួរចម្លើយរបស់ខ្មែរក្រហម ។

បច្ចុប្បន្នទីតាំងនេះនៅតែមានព្រៃដុះជិតដដែល ប៉ុន្តែនៅជុំវិញបរិវេណនេះមានផ្ទះប្រជាជនដែលមកពីឆ្ងាយៗមកស្នាក់នៅដើម្បីធ្វើស្រែ និងដាំបន្លែសម្រាប់ដោះស្រាយជីវភាពរបស់ពួកគេ ។

*ព្រៃខ្មោច (ទីតាំងសម្លាប់)*

*លេខកូតភូមិសាស្រ្ត ០៤០៦១១*

*រយៈកំពស់* **(N) 12º 17'06:35"**

*រយៈទទឹង* **(E) 104º 32'58:52"**

ព្រៃខ្មោច ជាព្រៃមួយដែលគ្មានមនុស្សរស់នៅ ហើយស្ថិតនៅឆ្ងាយដាច់ស្រយាលពីភូមិដែលមានប្រជាជនរស់នៅ ។ ទីតាំងនេះស្ថិតនៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ការធ្វើដំណើរទៅកាន់ទីតាំងព្រៃខ្មោចមិនមែនងាយស្រួលឡើយ គឺត្រូវឆ្លងកាត់អូរ ព្រៃរបោះ និងផ្លូវពិបាក ។ កាលពីជំនាន់សង្គមរាស្រ្តនិយម និងលន់ ណុល ព្រៃនេះគឺជាព្រៃសម្រាប់កប់ខ្មោចប្រជាជនដែលបានស្លាប់ដោយសារជម្ងឺ ឬឧបត្តវហេតុផ្សេងៗ ។ លុះមកដល់សម័យខ្មែរក្រហមព្រៃនេះក៏នៅតែជាកន្លែងដែលកប់ខ្មោចដដែល ។ ប៉ុន្តែបច្ចុប្បន្ននេះ គឺជាព្រៃដែលបោះបង់ចោលគ្មានមនុស្សរស់នៅ ។ ប្រធានភូមិអូរលាចឈ្មោះ អ៊ុក ម៉ែត បានប្រាប់ថាមានរណ្តៅសាកសពលើសពី១០រណ្តៅនៅក្នុងទីតាំងព្រៃខ្មោចនេះ ។ ចំណែកឯជនរងគ្រោះវិញ ម៉ែត គ្រាន់តែប្រាប់ថាមានចំនួនលើសពី៥០នាក់ ព្រោះពេលដែលគាត់បានទៅឃើញការគាស់នៅឆ្នាំ១៩៨១គឺមានចំនួនប៉ុណ្ណោះមែន ប៉ុន្តែការគាស់នេះនៅមិនទាន់អស់នៅឡើយទេ ។ អ៊ុក គឿន អាយុ ៣៩ឆ្នាំ ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល បានប្រាប់ខ្ញុំថាគាត់បានចូលរួមគាស់រណ្តៅសាកសពមួយក្នុងចំណោមរណ្តៅទាំងជាង១០ដែលបានគាស់ ។ បន្តិចក្រោយមក គឿន បានក្លាយទៅជាអ្នកដឹកជញ្ជូនឆ្អឹងទៅវិញ ។ អដ្ឋិធាតុដែល គឿនបានដឹកជញ្ជូននោះគឺបានដឹកយកទៅតម្កល់ទុកនៅក្នុងបន្ទាយ

ទាហានមួយដែលស្ថិតនៅក្នុងភូមិអូរលាច ។ អដ្ឋិធាតុទាំងនោះគឺមានចំនួន៣រទេះគោ ។ គឿន បានដឹកអដ្ឋិធាតុទាំងនេះដោយផ្ទាល់ ។ គឿន បានប្រាប់ថាគឺជាអដ្ឋិធាតុជនរងគ្រោះដែលបានស្លាប់ក្នុងឆ្នាំ១៩៧៧-៧៨ ។ ចំពោះការបញ្ជូនមនុស្សមកសម្លាប់នៅទីតាំងព្រៃខ្មោចនេះ បានត្រូវរាយការណ៍ប្រាប់ពីឈ្មោះ នុង គួ អាយុ៦៣ឆ្នាំ ជាសមាជិកក្រុមប្រឹក្សាឃុំបន្ទាយព្រាលថា បានយកមកពីមន្ទីរសន្តិសុខមួយកន្លែងដែលស្ថិតនៅចម្ងាយប្រហែល១គីឡូម៉ែត្រប៉ុណ្ណោះពីទីតាំងសម្លាប់ប៉ែកខាងត្បូង ។ មន្ទីរសន្តិសុខនោះគឺជាមន្ទីរសន្តិសុខប្រចាំឃុំបន្ទាយព្រាលដែលមានឈ្មោះថា "គុកអូរលាច" ។ ទីតាំងសម្លាប់នេះ មិនបានបន្សល់ទុកនូវអ្វីដែលជាភស្តុតាងឡើយនៅក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រៅពីភាពក្រហេងក្រហូងនៃរណ្តៅដែលបានបាក់ស្រុតបន្ទាប់ពីសាកសពបានទ្រោមរឡេះរលួយសាច់អស់ទៅ ។ នៅក្នុងទំហំប្រមាណ២០០ម៉ែត្របួនជ្រុងនៃបរិវេណព្រៃខ្មោច គឺជាទីតាំងសម្លាប់របស់ខ្មែរក្រហម ។ ក្រោយការគាស់រណ្តៅសាកសពនៅឆ្នាំ១៩៨១ ដែលមានចំនួនជាង១០រណ្តៅនេះទៅ នៅមានរណ្តៅជាច្រើនទៀតដែលមិនទាន់បានគាស់ ។

*អូរលាច (ទីតាំងសន្តិសុខ)*

*លេខកូតភូមិសាស្ត្រ ០៨០៦១២*

*រយៈកំពស់* **(N) 12º 16' 42:64"**

*រយៈទទឹង* **(E) 104º 32'52:71"**

គុកអូរលាច ស្ថិតនៅក្នុងភូមិអូរលាច ឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ មន្ទីរនេះបានបង្កើតឡើងនៅឆ្នាំ១៩៧៦ ហើយមានដំណើរការរហូតដល់ចុងឆ្នាំ១៩៧៨ ។ ដោយសារតែភាពដំណើរនៃមន្ទីរសន្តិសុខនេះហើយបានជាធ្វើឲ្យមនុស្សជាច្រើននាក់បានត្រូវសម្លាប់ស្ទើរតែរាល់ថ្ងៃនៅទីតាំងសម្លាប់ព្រៃខ្មោច ។ មន្ទីរសន្តិសុខនេះ គឺជាមន្ទីរសន្តិសុខរបស់ស្រុក២០ (រលាប្អៀរជើង) ដែលមានអ្នកទោសជាប្រជាជន១៧មេសា, ប្រជាជនមូលដ្ឋាន និងកម្មាភិបាលខ្មែរក្រហម ។ អ្នកទោសទាំងអស់តម្រូវឲ្យធ្វើការគ្រប់ៗគ្នា មិនថាអ្នកទោសប្រភេទធ្ងន់ ឬស្រាលឡើយ ។ ការធ្វើការរបស់អ្នកទោសត្រូវស្ថិតក្នុងការឃ្លាំមើលរបស់កងឈ្លបប្រចាំសន្តិសុខ ។ អ្នកទោសធ្ងន់ មានតួនាទីជាអ្នកគាស់គល់ឈើទាំងដើងជាប់ខ្នោះ ។ ចំណែកអ្នកទោសស្រាលវិញមានដាក់ច្រវ៉ាក់ចាក់សោនៅនឹងចង្កេះជាជួរៗចំនួនបួន-ប្រាំនាក់ រួចបណ្តើរឲ្យធ្វើការជាអ្នកដាំដំឡូង កាប់ចម្ការ ។ល ។ ការងារពេលកម្មរបស់អ្នកទោសគឺមានកំណត់ម៉ោងពេលត្រឹមត្រូវណាស់ នៅពេលព្រឹកចាប់ផ្តើមចេញពីព្រលឹម និងចូលមកក្នុងគុកវិញនៅម៉ោង១២ថ្ងៃត្រង់ ។ ពេលហូបបាយហើយត្រូវចេញទៅធ្វើការទៀត

រហូតដល់ពេលព្រលប់ទើបត្រឡប់វិញ ។ ក្រៅពីការដោះស្រាយប្រចាំថ្ងៃរបស់អ្នកទោសទៅ នៅមានការសួរចម្លើយទៀតសម្រាប់អ្នកទោស ។ មានមន្ទីរសួរចម្លើយមួយដែលគ្មាននរណាដឹងទាល់តែសោះ លុះដល់បែកថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ ទើបប្រទះឃើញមានគុ កៅអី និងក្រដាសស្នាមជាច្រើនដែលស្ថិតនៅរាយប៉ាយយ៉ាងគ្មានសណ្ដាប់ធ្នាប់ ។ នុង គួរ អាយុ៦៣ឆ្នាំ ជាអតីតប្រធានឃុំបន្ទាយព្រាលបានប្រាប់ថា ការសួរចម្លើយនេះមានធ្វើទារុណកម្មផង ព្រោះគាត់បានសង្កេតឃើញមានឧបករណ៍មួយចំនួនដូចជា ខ្សែតី, ដំបង និងព្រនុងជាដើម នៅក្រោយថ្ងៃរំដោះ ។ គួរ បានប្រាប់ទៀតថា មានខ្មោះឈើជាច្រើនទៀតដែលស្ថិតនៅប្រផេះប្រផាំងពេញបរិវេណនៃមន្ទីរសន្តិសុខអូរលាចនេះ ។ ចំពោះស្ថានភាពខាងក្នុងមន្ទីរនេះវិញ គ្មាននរណាម្នាក់បានឃើញ និងដឹងច្បាស់ឡើយ ព្រោះជាកន្លែងហាមឃាត់យ៉ាងតឹងរ៉ឹងបំផុត ។ «ខ្ញុំបានដឹងរឿងនេះយ៉ាងច្បាស់ថា គ្មានការអនុញ្ញាតិឲ្យមានការសួរសុខទុក្ខអ្វីបន្តិចសោះពីបងប្អូនញាតិមិត្តរបស់អ្នកទោស ទោះជាមានការទទូចសុំយ៉ាងណាក៏ដោយ ។ ខ្ញុំនិយាយនេះគឺសម្រាប់តែអ្នកទោសដែលជាប្រជាជនមូលដ្ឋានប៉ុណ្ណោះ ។ ចំណែកអ្នកទោសដែលជាប្រជាជន១៧មេសា និងកម្មាភិបាលខ្មែរក្រហមដែលជាប់ចោទពីបទល្មើសផ្សេងៗ មិនដែលមាននរណាមកស្នើសុំសួរសុខទុក្ខឡើយ» ។ នេះជាសម្ដីរបស់ គួរ ផ្ទាល់ដែលបាននិយាយប្រាប់តាមរឿងរ៉ាវដើមទាំងអស់ដែលអតីតមិត្តភក្ដិរបស់គាត់ម្នាក់ឈ្មោះ ខួយ បាននិយាយប្រាប់កាលពីជំនាន់ខ្មែរក្រហម ។ ខួយ គឺជា សន្តិសុខយាមគុកនៅអូរលាច ។ ខួយ បានប្រាប់បន្ថែមទៅ គួរ ថាមានការនាំមនុស្សយកទៅសម្លាប់នៅព្រៃខ្មោចដោយថ្មើរជើង ព្រោះពីមន្ទីរសន្តិសុខទៅកាន់កន្លែងសម្លាប់មានចម្ងាយប្រមាណតែមួយគីឡូម៉ែត្រប៉ុណ្ណោះ ។ មានកម្មាភិបាលខ្មែរក្រហមម្នាក់ឈ្មោះ សឿន បានត្រូវចាប់ខ្លួនមកដាក់នៅក្នុងមន្ទីរសន្តិសុខអូរលាចដែរ ហើយក្រោយមកត្រូវបាននាំយកទៅសម្លាប់ចោលនៅព្រៃខ្មោច ដោយសារតែរឿងបានខូចសីលធម៌ជាមួយនារីជាអ្នក១៧មេសាម្នាក់រហូតមានផ្ទៃពោះ ។ នារីនោះ ក៏ត្រូវបាននាំយកទៅសម្លាប់ចោលដោយ សឿន ដែលជាអ្នករួមស្នេហាជាមួយដែរ គឺមុនពេលដែល សឿន ត្រូវបានចាប់ខ្លួន ។ សឿន ធ្វើយ៉ាងនេះក៏ព្រោះតែមិនចង់ឲ្យបែកការណ៍ពីកំហុសឆ្គងរបស់ខ្លួន ព្រោះកាលនោះ(១៩៧៥-៧៦) សឿន គឺជាប្រធានកងឈ្លបប្រចាំស្រុក២០ ។ ក្រៅពី សឿន ទៅនៅមានកម្មាភិបាលផ្សេងទៀតក៏ត្រូវទទួលទណ្ឌកម្មដូចគ្នាដែរ ឲ្យតែអង្គការបានតាមដានទៅឃើញថាមានកំហុស ទោះជាកំហុសនោះស្រាល ឬធ្ងន់ក៏ដោយ ។

រហូតមកដល់បច្ចុប្បន្ន អតីតមន្ទីរសន្តិសុខអូរលាចដែលជាសន្តិសុខប្រចាំស្រុក២០ បានក្លាយទៅជាទីជម្រកនៃសត្វតិរច្ឆាន និងសត្វព្រៃយ៉ាងកណ្ដោចកណ្ដែង ។ ខ្ញុំបានដើរសំដៅទៅកាន់ទីនោះមួយៗ ក្នុងបំណងប្រាថ្នាទៅពិនិត្យឲ្យបានផ្ទាល់ភ្នែកនូវវត្ថុតាងនានាដែលបានបន្សល់ទុក ប៉ុន្តែត្រូវអាក់ខានវិញ ព្រោះមិនអាចទៅ

*បានដោយសារព្រៃក្រាស់ៗពេក និងគ្មានផ្លូវផង។ ការកំណត់យកចំនុចខ្សែស្រប និងរយៈកំពស់នៃម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក ក៏បានធ្វើឡើងនៅជាយព្រៃនៃបរិវេណមន្ទីរនោះតែម្តង។ ក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខនេះបានរលាយទៅជាមួយនឹងអ្នកដឹកនាំវាដែលបានត្រូវសម្លាប់ និងបណ្តេញឲ្យរត់ភៀសខ្លួនទៅកាន់ទីកន្លែងឆ្ងាយៗដែលមិនអាចរកឃើញរហូតដល់សព្វថ្ងៃនេះ។*

## ២) ស្រុកបរិបូរ

*ព្រៃរូងខ្លា (ទីតាំងសន្តិសុខ)*

*លេខកូតភូមិសាស្ត្រ ០៤០១០៥*

*រយៈកំពស់* **(N) 12º 22' 40:38"**

*រយៈទទឹង* **(E) 104º 22' 00:12"**

*ព្រៃរូងខ្លា ស្ថិតនៅក្នុងឃុំពេជ្រចង្វារ ស្រុកបរិបូរ គឺជាព្រៃដែលគ្មានមនុស្សរស់នៅដែលមានចម្ងាយ ៦គីឡូម៉ែត្រពីភូមិប្រជាជន។ ខ្ញុំបានធ្វើដំណើរទៅដល់ទីកន្លែងនោះដោយរថយន្តតាមផ្លូវខ្សាច់ និងបានឆ្លងកាត់តាមព្រៃជាច្រើនដូចជា ព្រៃឈើទាល, ព្រៃអ្នកតាព្រះស្តេច, ព្រៃក្រាំងតាមាស...ៗល។ សភាពស្ងប់ស្ងាត់នៃព្រៃបានធ្វើឲ្យអារម្មណ៍របស់ខ្ញុំនឹកឮរម្ភចំពោះបញ្ហាសុវត្ថិភាពនៃក្រុមស្រាវជ្រាវយើង។ ព្រៃរូងខ្លា មានប្រវត្តិពីបូរាណមកថា កាលដើមឡើយព្រៃនេះមានសុទ្ធតែរូងខ្លាពាសពេញ និងគ្មាននរណាហ៊ានដើរឆ្លងកាត់ឡើយ។ ប៉ុន្តែដល់សម័យក្រោយៗមកទៀត ដោយសារតែសង្គ្រាមញឹកញាប់ពេក ធ្វើឲ្យសត្វព្រៃទាំងនោះត្រូវរត់ និងស្លាប់អស់។ លុះមកដល់សម័យដែលគ្រប់គ្រងដោយខ្មែរក្រហម ព្រៃនេះបានក្លាយទៅជាកន្លែងសម្លាប់មនុស្សទៅវិញ។ ក្រោយថ្ងៃរំដោះ៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនក្នុងឃុំបានហៅទីនោះថាជាកន្លែងកប់ខ្មោចមនុស្ស។ បច្ចុប្បន្ន មានប្រជាជនមួយចំនួនបានមកកាប់ឆ្ការព្រៃដើម្បីធ្វើស្រែខ្លះហើយ។ ស វង់ អាយុ៥៨ឆ្នាំ រស់នៅក្នុងឃុំពេជ្រចង្វារ បានប្រាប់ថា ទើបតែមកដល់ទសវត្សរ៍ទី៩០ទេ ដែលមានប្រជាពលរដ្ឋមួយចំនួនបានមករានដីខ្លះៗនៅក្នុងបរិវេណព្រៃរូងខ្លានេះ ដើម្បីធ្វើស្រែចម្ការ។ ចំពោះរឿងរ៉ាវដែលទាក់ទងនឹងការសម្លាប់មនុស្សនៅព្រៃរូងខ្លានេះ វង់ បាននិយាយថា ពុំមាននរណាម្នាក់បានដឹងប្រាកដឡើយ ព្រោះការសម្លាប់នេះគឺជាការសម្ងាត់របស់ខ្មែរក្រហម។ ប៉ុន្តែ វង់ បាននិយាយថាបានឃើញនៅឆ្នាំ១៩៨៣ នូវស្លាកស្នាមរណ្តៅ កម្ទេចកម្ទីខោអាវ ឆ្អឹង និងឧបករណ៍សម្លាប់ផ្សេងទៀតដែលបានបន្សល់ទុកនៅទីនោះ នៅពេលដែលគាត់បានដើរមកឃ្វាលក្របី។ វង់ បានសន្និដ្ឋានថា ជនរងគ្រោះភាគច្រើនបំផុតគឺជាទាហាន*

ខ្មែរក្រហមដូចគ្នាដែលត្រូវបានសម្លាប់ដោយបានធ្វើខុសនឹងអង្គការ ។ មានរណ្តៅពី១០ទៅ១៥រណ្តៅ ដែលក្នុងរណ្តៅមួយៗមានទំហំទទឹង២ម៉ែត្រ និងបណ្តោយ៣ម៉ែត្រ ។ វង់ បានបន្ថែមថា មានសាកសពចាប់ពី៥នាក់ឡើងទៅក្នុងមួយរណ្តៅ ។ ចំណែកឯសាកសពវិញ គឺមានចំនួនពី៥០ទៅ១០០នាក់ ។ ការប៉ាន់ស្មានចំនួនសាកសពនេះគឺដោយសារតែការគាស់រុករើរណ្តៅទាំងឡាយនៅព្រៃរូងខ្លានេះដើម្បីរកមាស និងវត្ថុមានតម្លៃនានា ។ អដ្ឋិធាតុទាំងអស់ដែលបានគាស់ឡើងគឺមិនត្រូវបានប្រមែប្រមូលទុកកន្លែងណាឡើយ ។ បំណែកខោអាវដែលបានស្គាល់ច្បាស់ថាជាសម្លៀកបំពាក់ត្រីអ៊ី(សម្លៀកបំពាក់ទាហាន) ក៏ត្រូវទុកចោលរហូតដល់មានការពុកផុយអស់ដោយសារកំដៅថ្ងៃ និងទឹកភ្លៀង ។ ការសម្លាប់នេះមិនត្រឹមតែទាហានប៉ុណ្ណោះទេគឺមានទាំងប្រជាជនខ្លះផងហើយក្នុងនោះក៏មានក្មេងៗដែរ ព្រោះ វង់ បានឃើញមានឆ្អឹងក្មេងៗជាច្រើន ។

ត្រពាំងល្ពាក់ ឬ ព្រៃខ្មោច (ទីតាំងសម្លាប់)

លេខកូតភូមិសាស្រ្ត ០៨០១០៦

រយៈកំពស់ **(N) 12º 22' 06:33"**

រយៈទទឹង **(E) 104º 22' 43:98"**

ត្រពាំងល្ពាក់ គឺជាទីតាំងសម្លាប់កុមារតូចៗដែលស្លាប់ដោយសារជម្ងឺ, អត់អាហារ, អស់កម្លាំង និងសម្លាប់ ។ ទីតាំងនេះស្ថិតនៅក្នុងព្រៃជ្រៅនៃទឹកដីឃុំពេជចង្វារ ស្រុកបរិបូរ ។ នៅកណ្តាលព្រៃជ្រៅយ៉ាងស្ងាត់ជ្រងំនេះ គ្មានអ្វីសម្រាប់សម្គាល់ទីតាំងសម្លាប់ត្រពាំងល្ពាក់បានទេ ក្រៅពីអ្នកនាំផ្លូវដែលខស្សរាហ៍ចេញចូលនោះ ។ ដើមព្រីងមួយដើមយ៉ាងធំ គឺជាម្លប់សម្រាប់ខ្ញុំជ្រកឲ្យផុតពីកំដៅថ្ងៃដ៏សែនក្តៅនាម៉ោងជាង១រសៀល ។ ខ្ញុំបានសំឡឹងមើលទៅត្រពាំងមួយដែលមានដើមរុក្ខជាតិតូចធំដុះយ៉ាងប្រជ្រៀតគ្នាតាមការចង្អុលបង្ហាញរបស់អ្នកនាំផ្លូវឈ្មោះ ស វង់ ។ ទីនោះហើយដែលជាទីតាំងសម្រាប់សម្គាល់ថាជាកន្លែងសម្លាប់កុមារតូចៗ ។ ប៉ុន្តែការសម្លាប់កុមារតូចៗមិនស្ថិតនៅក្នុងត្រពាំងនេះទេគឺស្ថិតនៅជាយៗត្រពាំងនេះទៅវិញ ។ គ្មានរណ្តៅសម្រាប់កប់ក្មេងៗនោះទេ ។ សាកសពត្រូវស្ថិតនៅកណ្តាលវាលទាំងថ្ងៃទាំងយប់ទាល់តែរឡេះរលួយ ឬត្រូវសត្វស៊ីអស់ ។ កែវ យិន អាយុ៨០ឆ្នាំជាស្មៀនឃុំពេជចង្វារបានរៀបរាប់ពីមូលហេតុនៃការស្លាប់នេះ ។ កុមារតូចៗដែលមានអាយុក្រោម៨ឆ្នាំទាំងអស់ ទោះជាកុមារនោះជាកូនរបស់ប្រជាជនមូលដ្ឋាន ឬប្រជាជន១៧មេសាក៏ដោយ គឺត្រូវប្រមូលមកកាន់ការដ្ឋានមួយដែលមានតែអ្នកគ្រូក្មេងៗជាអ្នកបង្ហាត់បង្រៀន និងមើលការខុសត្រូវ ។ អក្សរមិនត្រូវបានបង្រៀនដល់ក្មេងៗទាំងនោះសូម្បីតែមួយតួឡើយ ប៉ុន្តែបែរជាជំនួសដោយការលត់ដំ

ខ្លួនឲ្យធ្វើពលកម្មទៅវិញ ។ ភាគច្រើននៃក្មេងៗនោះគឺមានអាយុត្រឹមតែ៥-៦ឆ្នាំប៉ុណ្ណោះ ។ ការងារសម្រាប់ពួកគេគឺលើកទំនប់ដីធំមួយដែលមានឈ្មោះថា "ទំនប់អូរអំពិល" ហើយដែលបានបន្សល់ទុករហូតដល់បច្ចុប្បន្ននេះ ។ ទំនប់ដីវែងឆ្ងាយមួយនេះបានក្លាយទៅជាទំបន់យ៉ាងសំខាន់ និងចាំបាច់បំផុតសម្រាប់ផ្ទុកទឹក និងបង្ហូរទឹកដែលហូរធ្លាក់ពីលើភ្នំមិនឲ្យធ្លាក់ទៅចូលទន្លេឡើយ ប៉ុន្តែវាបានបង្ហូរទឹកឲ្យចូលក្នុងអាងស្តុបទឹកធំៗរបស់ប្រជាជនក្នុងការបង្កបង្កើនផល, ធ្វើចម្ការ និងធ្វើស្រែប្រាំង ។ ផែនការលើកទំនប់មួយនេះ បានត្រូវផ្តួចផ្តើមឡើយដោយខ្មែរក្រហមកាលពីឆ្នាំ១៩៧៦ ។ ក្នុងផ្នត់គំនិតដ៏អស្ចារ្យនេះ ខ្មែរក្រហមបានទម្លាក់ការងារនេះទៅឲ្យកុមារតូចៗដែលមានអាយុ៥-៦ឆ្នាំជាអ្នកអនុវត្តក្នុងនាមជាអ្នកគំរូដល់បណ្តាយុវជន យុវនារីទាំងឡាយ ។ ការដ្ឋានសម្រាប់កុមារស្នាក់នៅបានសាងសង់ឡើងនៅក្នុងព្រៃដាច់តែឯង ។ ពុំដែលមានការអនុញ្ញាតិម្តងណាឡើយចំពោះការមកសួរសុខទុកពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ក្មេងៗទាំងនោះ ។ ការបំបែកនេះបានធ្វើឲ្យក្មេងៗដែលភាគច្រើនជាកូនរបស់ប្រជាជនជម្លៀសមកពីភ្នំពេញមានការអណោចអធមជាពន់ពេក ព្រោះការរស់នៅប្រកបទៅដោយភាពគ្មានសណ្តាប់ធ្នាប់ និងហូបចុកមិនឆ្អែត ។ ការងារវែកដី កាប់ដីលើកទំនប់បានត្រូវអនុវត្តឡើងជារៀងរាល់ពេលព្រឹកព្រលឹមរហូតដល់ម៉ោងដាង១១ថ្ងៃត្រង់ទើបមានការអនុញ្ញាតិឲ្យឈប់ដើម្បីហូបបាយរួម ។ បន្ទាប់មកត្រូវធ្វើពលកម្មបន្តទៀតរហូតដល់ពេលព្រលប់ ។ របបអាហារប្រចាំថ្ងៃរបស់កុមារទាំងនោះគឺបបរកន្លះវែកក្នុងមួយពេល ។ ទំនប់អូរអំពិលដែលមានកំពស់៥ម៉ែត្រទទឹងទំនប់៧ម៉ែត្រ និងបណ្តោយប្រហែលពាគីឡូម៉ែត្រ បានត្រូវលើករួចរាល់ជាស្ថាពរនៅក្នុងរយៈពេលតែជាងមួយឆ្នាំក្រោយមក ។ ជាមួយនឹងទំបន់ដីធំអស្ចារ្យនេះលេចរូបរាងឡើង ជីវិតកុមារតូចៗរាប់ពាន់នាក់បានត្រូវសម្លាប់ និងស្លាប់ដោយអត់អា ហារ, ជម្ងឺហើម ។ ការសម្លាប់កុមារបានប្រព្រឹត្តិទៅនៅពេលដែលការមិនគោរពវិន័យកើតឡើង ។ ការលួចរត់ទៅផ្ទះទៅជួបជាមួយឪពុកម្តាយ គេចវេះពីការងារ និងមិនព្រមធ្វើការងារ បានត្រូវព្រមានដោយសម្លាប់ដើម្បីកុំឲ្យមានអ្នកផ្សេងធ្វើគំរូតាម ។ ក្រៅពីនេះទៅ នៅមានកុមារជាច្រើននាក់ទៀតបានស្លាប់ជាហូរហែរ ជួនកាលស្លាប់នៅពេលព្រលឹមឡើងពេលដែលត្រូវងើបទៅធ្វើការងារបន្ត និងជួនកាលទៀតបានស្លាប់ទាំងភារកិច្ចនៅជាប់នឹងខ្លួន ។ ភាពវេទនាទាំងនេះមិនបានត្រូវមើលថែឡើយពីអង្គការបក្សដែលមានអ្នកគ្រូជាអ្នកមើលការខុសត្រូវលើកុមារទាំងនោះ ។ ការបញ្ជូនកុមារថ្មីៗមកក៏មានកាន់តែច្រើន ចំណែកកុមារដែលស្លាប់ជារៀងរាល់ថ្ងៃក៏មានច្រើនណាស់ដែរ ។ កុមារដែលនៅរស់ គឺមានតួនាទីជាអ្នកជញ្ជូនកុមារដែលបានស្លាប់យកទៅបោះចោលនៅព្រៃនៅពេលបានបញ្ចប់ការងារលើកទំនប់នាពេលថ្ងៃត្រង់ និងពេលល្ងាចរួចរាល់មក ។

ព្រៃខ្មោចគឺជាព្រៃដែលមានសុទ្ធតែខ្មោចក្មេងៗទាំងអស់ ។ សាកសពក្មេងៗត្រូវស្ថិតនៅគរដេីងលេីគ្នាជុំវិញត្រពាំងមួយឈ្មោះថា ត្រពាំងល្អាក់ ។ ការងារជាប្រចាំនៃការសែងខ្មោចក្មាងឯងយកទៅចោល បានធ្វេីឲ្យភាពក្រែងរអែង និងភាពភ័យខ្លាចខ្មោចលង ត្រូវវិនាសអស់ពីអារម្មណ៍របស់កុមារក្មេងៗទាំងឡាយ ។ កែវ យិន គឺជាអ្នកដែលបានឃេីញហេតុការសែងខ្មោចយកទៅចោលដោយផ្ទាល់ភ្នែក ។ ជារៀងរាល់ថ្ងៃ យិន បានប្រទះឃេីញក្មេងៗសែងខ្មោចក្មេងៗដូចគ្នាយកទៅទម្លាក់ចោល ហេីយបានធ្វេីដំណេីរត្រឡប់មកការដ្ឋានវិញ ។ យិន គឺជាកងកុមារធំៗ ព្រោះមានអាយុចាប់ពី៨ឆ្នាំឡេីងទៅ ។ យូរៗម្តង យិន បានឃេីញមានសត្វព្រៃដូច ជាសត្វជ្រូកព្រៃ និងសត្វដទៃទៀតបាននាំគ្នាហែកសពក្មេងៗទាំងនោះធ្វេីជាអាហារបំពេញក្រពះ ។ យិន បានចាត់ទុកការធ្វេីទារុណកម្មទាំងនេះមកលេីកុមារតូចៗថា ជាការបំផ្លាញសសរទ្រូងរបស់ប្រទេសជាតិនាថ្ងៃខាងមុខ ។ ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ យិន បានប្រាប់ថានៅមានកុមារខ្លះនៅមានជីវិតនៅឡេីយ ហេីយពួកកុមារទាំងនោះបានផ្ញេីខ្លួននៅជាមួយប្រជាជនមូលដ្ឋាននាភូមិតាំងត្រពាំង និងភូមិមួយចំនួនទៀតដែលស្ថិតក្នុងឃុំពេជ្រចង្វារ ស្រុកបរិបូរ ។ ប៉ុន្តែនៅពេលក្រោយៗមកទៀត កុមារទាំងនោះបានត្រូវនាំយកមករស់នៅស្រុកកំណេីតរបស់ខ្លួនវិញដោយឪពុកម្តាយរបស់ពួកគេ ។

នៅនឹងភូមិតាំងត្រពាំង និងនៅជុំវិញបរិវេណនៃទីតាំងសម្លាប់ ក៏ដូចជានៅក្បែរទំនប់អូរអំពិល ខ្ញុំមិនបានជួបជនរងគ្រោះជាអតីតកុមារដែលធ្លាប់បានធ្វេីពលកម្មលេីកទំនប់អូរអំពិលណាម្នាក់ដេីម្បីសាកសួរយកពត៌មានពីពួកគាត់ឡេីយ ។ ប៉ុន្តែគ្រាន់តែបានដឹងតាមរយៈការផ្តល់ពតមានពីលោក កែវ យិន នូវចំនួនសាកសពដែលបានស្លាប់នៅនឹងទីតាំងព្រៃខ្មោចថាមានចំនួនរាប់រយនាក់ ហេីយដែលជនរងគ្រោះទាំងនោះគឺជាកុមារដែលមានអាយុតិចជាង៨ឆ្នាំ ។ ភាគច្រេីនបំផុតនៃសាកសពគឺស្លាប់ដោយជម្ងឺហេីម ខ្វះជីវជាតិ និងអត់អាហារ ។ ឯមួយភាគទៀតគឺស្លាប់ដោយសារតែការមិនគោរពវិន័យ ។ គ្មានរណ្តៅសម្រាប់កប់សាកសពទេ ។ សពខ្លះបានក្លាយទៅជាចំណីរបស់សត្វព្រៃ ។

## ៣) ស្រុកទឹកផុស

*ក្រាំងគ្នោត (ទីតាំងសម្លាប់)*

*លេខកូតភូមិសាស្ត្រ ០៤០៨០៥*

*រយៈកំពស់* **(N) 11º 55' 57:16"**

*រយៈទទឹង* **(E) 105º 24' 34:68"**

ទាហានខ្មែរក្រហមជាច្រើននាក់បានត្រូវសម្លាប់ដោយការបញ្ឆោតថាឲ្យទៅទប់ទល់នឹងកងទពយួននៅព្រំប្រទល់ ដោយគ្រាន់តែបញ្ជូនមកស្តុបទុកនៅតាមព្រំប្រទល់ស្រុកទឹកផុសនិងខេត្តកំពង់ស្ពឺសិន ដើម្បីរង់ចាំទទួលបញ្ជាពីអង្គការ ។ មូលហេតុនៃការដឹកទាំងរថយន្តមកនេះ គឺដោយសារតែមានការបែកបាក់ផ្ទៃក្នុងរវាងភូមិភាគនឹងភូមិភាគនៃការកាន់ក្តាប់របស់ខ្មែរក្រហម ។ សោភឹម ត្រូវបានតាមរកចាប់ខ្លួនរហូតទាល់តែមានការធ្វើអត្តឃាតដោយខ្លួនឯង ។ ចំណែកឯកម្មាភិបាលឯទៀតដែលនៅក្រោមបង្គាប់របស់សោភឹម ក៏ត្រូវតាមរកចាប់ខ្លួនដូចគ្នាដែរ ។ការប្រមែប្រមូលនេះបានធ្វើឲ្យកម្មាភិបាលភូមិភាគបូព៌ាភ័យខ្លួនរហូតបាត់បង់នូវភាពក្លាហានដែលខ្លួនធ្លាប់មានពីមុនមក ។ ការសម្លាប់បានកើនឡើងទ្វេរដងនៅចុងឆ្នាំ១៩៧៧និងបន្តរហូតដល់ចុងឆ្នាំ១៩៧៨ទៀត ។

ក្រាំងត្នោត គឺជាទីតាំងមួយដែលត្រូវបានជ្រើសរើសជាកន្លែងកប់សាកសពទាហានខ្មែរក្រហមខាងភូមិភាគបូព៌ា ។ នៅមានស្នាកស្នាមជាទួលធំៗចំនួនពាកន្លែង ដែលស្ថិតនៅរាងជាមុំចង្រ្កាននៃដីស្រែរបស់លោកតាមូល នាពេលបច្ចុប្បន្ននេះ ។ ប្រជាពលរដ្ឋដែលមកពីភូមិផ្សេងដូចជាឈ្មោះ វង់ សយ អាយុ៤៩ឆ្នាំជាដើម ហើយដែលបានមកធ្វើស្រែនៅក្បែរដីស្រែរបស់តាមូល បានជូនដំណើរខ្ញុំនិងក្រុមស្រាវជ្រាវទៅកាន់ទីតាំងសម្លាប់អូរស្ពាន ព្រមទាំងបានចង្អុលបង្ហាញពីទួលទាំង៣នោះថាជាកន្លែងកប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។ គ្រូក្រៅប្រពន្ធ័អប់រំនៃសាលាបឋមសិក្សាភូមិរលុងថ្មីឈ្មោះ ស៊ុំ រឿន អាយុ៤៤ឆ្នាំ បានរៀបរាប់ប្រាប់ទីទីតាំងនេះយ៉ាងលម្អិតដល់ក្រុមខ្ញុំ ។ មុននឹងចូលធ្វើគ្រូក្រៅប្រពន្ធ័អប់រំ រឿន ខស្សរាហ៍ទៅឃ្វាលគោនៅទីតាំងនោះណាស់ព្រោះមានស្មៅច្រើនហើយបានអង្គុយលេងនៅលើទួលនោះដង ។ នៅពេលដែល រឿន អង្គុយយូរបន្តិចទៅ គាត់តែងតែនឹកឃើញរឿងរ៉ាវដែលបានកើតឡើងកាលពីជំនាន់ដែលគ្រប់គ្រងដោយខ្មែរក្រហមនៅនឹងគំនិតរបស់គាត់ជានិច្ច ព្រោះអ្វីដែលគាត់បានឃើញគឺជាអ្វីដែលគាត់បានចាំអស់មួយជីវិត ។ រឿន បានរំឭកពីការគិតឃើញរបស់គាត់ប្រាប់ខ្ញុំថា មានទាហានជាច្រើនបានត្រូវដឹកមកតាមរថយន្តហ្សេអ៊ឹមសេ (GMC) មកទម្លាក់នៅក្រាំងត្នោតនេះ ។ ទាហានទាំងនោះបានត្រូវដោះខោអាវចេញពីខ្លួន, ចងដៃមកក្រោយ និងរុំក្រណាត់នៅនឹងមុខដោយប្រាប់ថានឹងធ្វើការផ្លាស់ប្តូរខោអាវចាស់ចោលហើយស្លៀកពាក់ខោអាវថ្មីវិញ ដើម្បីត្រៀមចាំទទួលអង្គការចុះមកពិនិត្យមុននឹងទៅកាន់ទីតាំងប្រយុទ្ធ ។ ប៉ុន្តែផ្ទុយស្រឡះពីអ្វីដែលពលទាហានទាំងនោះបានគិត ។ ការសម្លាប់ក៏បានកើតឡើងភ្លាមៗគឺចាប់ពីខែកក្កដា ឬសីហាឆ្នាំ១៩៧៨ទៅ ។ សៅ ចិន អាយុ៦៦ឆ្នាំ ជាប្រជាជនរស់នៅភូមិរលុង ឃុំទួលខ្ពស់ ស្រុកទឹកផុស បានប្រាប់ពីចំនួនរថយន្តដែលដឹកអ្នកទោសជាទាហានមកថាមានចំនួន៧រថយន្តធំៗ ហើយដែលក្នុងមួយរថយន្តៗមានទាហានចំនួនប្រហែល៧០ នាក់ ។

ចិន បន្តទៀតថាទាហានទាំងនេះគឺជាទាហានដែលបានបញ្ជូនមកពីភូមិភាគបូព៌ា ដែលតម្រូវឲ្យមកធ្វើព្រលានយន្តហោះកំពង់ឆ្នាំង និងការពារទល់ដែន ។ មិនយូរទេ បន្ទាប់ពីបានដឹកមកភ្លាមគឺយកមកសម្លាប់ភ្លាមដោយគ្មានការសួរនាំអ្វីទាំងអស់ ។ ការសម្លាប់បានធ្វើឡើងជាមួយនឹងឧបករណ៍ដូចជាកាំភ្លើង ដំបង ភ្លៅរទេះ និងត្បូងចប ។ សាកសពជាច្រើនរយនាក់ដែលបានបន្សល់ទុកក្រោយការសម្លាប់គ្មានត្រូវបានអូសយកទៅដាក់ក្នុងរណ្តៅកប់ឡើយ ។ រឿន ដែលជាអ្នកឃើញហេតុការនេះផ្ទាល់ភ្នែកបានអធិប្បាយថា សាកសពដែលបានសម្លាប់ទាំងប៉ុន្មានមិនបានជីករណ្តៅសម្រាប់កប់ទេ គឺបានត្រឹមតែប្រមូលដោយត្រាក់ទ័រដាក់មួយពំនូកៗហើយដីកដីកប់ពីលើ ។ មានត្រាក់ទ័រប្រមាណពី៣គ្រឿងឡើងទៅសម្រាប់ប្រចាំការដីកដីលប់សាកសពដែលបានសម្លាប់ ។ រឿន និយាយទៀតថា បើតាមគាត់បានឃើញ និងរាប់ទៅឃើញថាមានជនរងគ្រោះចំនួនជាង១០រថយន្តGMC បានត្រូវដឹកយកមកកាន់ភូមិរលុងទាំងអស់ ប៉ុន្តែដោយឡែកមានចំនួន៧ឡានបានត្រូវដឹកមកកាន់ទីតាំងសម្លាប់ក្រាំងត្នោត ។ ចំណែកឯប៉ុន្មានឡានទៀត បានត្រូវបែងចែកទៅតាមទីតាំងផ្សេងៗទៀតដូចជាអូរស្គាន ឬឆ្កែជ្រុំ, អូរចា, និងខាងជើងភ្នំកញ្ជើបាយ ។ ការសម្លាប់នៅទីតាំងនេះ មិនត្រូវបានប្រមូលផ្តុំតែ៣ពំនូកដែលបានមើលឃើញនាពេលបច្ចុប្បន្ននេះទេ គឺនៅមានច្រើនកន្លែងទៀតដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីគ្នា ។ ប៉ុន្តែពំនូកទាំងនោះបានត្រូវដីកកាស់កកាយដោយអ្នកស្រុកនៅក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ ដើម្បីស្វែងរកមាសពេជ្រដែលនៅជាប់នឹងខ្លួនសាកសព ។

ទីតាំងសម្លាប់ក្រាំងត្នោតនេះ គឺជាទីតាំងដែលមានសម្លាប់ភាគច្រើនបំផុតជាទាហានខ្មែរក្រហមគ្នាឯង ។ ឯប្រជាជន១៧មេសា ប្រជាជនមូលដ្ឋាន និងអ្នកឯទៀត មិនបានយកទៅសម្លាប់នៅទីនេះភាគច្រើនឡើយ គឺច្រើនយកទៅសម្លាប់នៅទួលអូរស្គាន ឬឆ្កែជ្រុំ និងនៅវត្តមង្គលខាន់ ។

សរុបជនរងគ្រោះដែលបានស្លាប់នៅទីតាំងក្រាំងត្នោតនេះទាំងអស់គឺមានចំនួនប្រហែល៨៩០នាក់ ។ មានពំនូកធំៗបីដែលសម្គាល់បានយ៉ាងប្រាកដថាជាពំនូកដែលបានកប់មនុស្សជាទាហានខាងសោភ័ម ។ នៅមានការសម្លាប់រាយប៉ាយទៀតដែលស្ថិតនៅក្នុងបរិវេណនេះដែរ ។

អូរស្គាន (ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខ)

លេខកូដភូមិសាស្រ្ត ០៤០៨០៦

**រយៈកំពស់ (N) 11º 55' 51:13"**

**រយៈទទឹង (E) 105º 20' 56:69"**

អូរស្ពាន ឬឆ្កកជ្រុំ គឺជាទីតាំងសម្ងាប់ជង និងមន្ទីរឃុំឃាំងផង ។ ហេតុការណ៍នេះបានកើតឡើងតាំងពីឆ្នាំ១៩៧៥មករហូតដល់ចុងឆ្នាំ១៩៧៨ ។ ជនរងគ្រោះដែលជាប្រជាជន១៧មេសាបានត្រូវឃាត់ខ្លួនឲ្យទៅរស់នៅតាមសហករណ៍នានាក្នុងឃុំត្រាវពន្លក (បច្ចុប្បន្នគឺជាឃុំទួលខ្ពស់) ។ ការរស់នៅនៃប្រជាជនទាំងនោះមិនបានរស់នៅដោយភាពឯករាជ្យទេ គឺត្រូវស្ថិតក្រោមការតាមដានរបស់ខ្មែរក្រហមដែលជាអ្នកត្រួតត្រាប្រចាំសហករណ៍និមួយៗ ។ ជាបណ្តើរៗខ្មែរក្រហមបានចាប់ផ្តើមចំរាញ់មនុស្សពីសហករណ៍ឲ្យទៅរស់នៅកន្លែងមួយផ្សេងដែលគ្មាននរណាដឹង ។ ការចម្រាញ់នេះ បានធ្វើឡើងតាមរយៈការស្រង់ប្រវត្តិរូប បូករួមនឹងការឃោសនាកុហកបោកប្រាស់របស់ពួកគេ(ខ្មែរក្រហម) ។ នរណាម្នាក់ក៏ចង់រស់ក្នុងសភាពដូចដើម(និយាយពីការរស់នៅដែលមិនទាន់មានថ្ងៃរំដោះ១៧មេសា)ដែរ ហើយប្រជាជនទាំងនោះតែងតែយល់ឃើញដូចៗគ្នាថា ការផ្លាស់ប្តូរសង្គមនេះ គឺជាការបំបែកហ្វូងមនុស្សដែលធ្លាប់តែរស់នៅប្រមូលផ្តុំ សប្បាយ និងហ៊ឺហាមកជាការរស់នៅបែបទុរគត ធ្វើការហួសកម្លាំង ហូបមិនគ្រប់គ្រាន់ ។ល ។ ប៉ុន្តែប្រជាជនទាំងនោះមិនបានយល់ពីជម្រៅនៃដួងចិត្តរបស់មនុស្សដែលបំពាក់ទៅដោយគោលនយោបាយដ៏ឆ្អិនឆ្អៅនៃបដិវត្តមហាអស្ចារ្យ មហាលោតផ្លោះនោះ ទេ ថាជាការចង់យកអ្នកដែលចង់ស្រណុកនោះទៅវាយចោលដើម្បីបំបាត់ភាពជាម្ចាស់លើទាសករ ភាពនាយទុន មូលធននិយម សក្តិភូមិ ដែលធ្លាប់បានកើតមានកាលពីពេលកន្លងមក ។ ដោយសារតែគោលនយោបាយ នេះ បានធ្វើឲ្យការរស់នៅក្នុងសហករណ៍តែក្នុងរយៈពេលខ្លីត្រូវរុះរើម្តងទៀតទៅកាន់កន្លែងផ្សេងតាមតែអង្គការកំណត់ទុកឲ្យ ។ ទីបំផុតនៃការផ្លាស់ប្តូរនេះ មន្ទីរសន្តិសុខមួយបានត្រូវបង្កើតឡើងដែរ ដែលមានឈ្មោះហៅថា "មន្ទីរសន្តិសុខអូរស្ពាន ឬឆ្កកជ្រុំ" ។ មន្ទីរសន្តិសុខនេះបានត្រូវបង្កើតឡើងនៅកណ្តាលព្រៃជ្រៅកាលពីឆ្នាំ១៩៧៥ ដែលមានសុទ្ធតែសត្វព្រៃសាហាវៗនៅជុំវិញ ។ ដើមឈើគ្រប់ប្រភេទបានដុះយ៉ាងប្រជៀតគ្នាស្ទើរតែរកផ្លូវដើរមិនមាននោះ បានត្រូវកាប់ឆ្ការសង់ជាមន្ទីរតូចធំតាមតែចិត្តនឹកឃើញ ។ ជនរងគ្រោះរាប់រយរាប់ពាន់នាក់បានត្រូវចែកគ្នារកទីស្នាក់អាស្រ័យក្នុងរោងដែលសង់រួច និងខ្លះទៀតស្នាក់នៅក្រោមដើមឈើធំៗដូចជាដើមខ្នុង ត្បែង...។ មុនដំបូងនៃការរស់នៅរបស់ប្រជាជនទាំងនោះគឺរស់ដោយភាពដោយឡែកពីគ្នា ទាំងការហូបចុក និងដេកពួន ។ ប៉ុន្តែយូរៗទៅ ការរស់នៅរបៀបនេះបានត្រូវរិតបន្តឹងទៅៗរហូតទាល់តែមានការហូបរួម និងដេករួម និងមានដាក់ខ្នោះឈើដែលធ្វើឡើងជាខ្សែៗ ។ តាងិន និងតាបេះ បានត្រូវស្គាល់យ៉ាងឥតប្រទ្បាំថាជាមនុស្សដែលបានគ្រប់គ្រងមន្ទីរសន្តិសុខនេះតាំងពីដើមរហូតដល់ចប់ ។ អ្នកទាំងនេះបានស្លាប់នៅពេលដែលកងទ័ពវៀតណាមវាយចូលមកកាលពីឆ្នាំ១៩៧៩ ។ ស៊ុំ រឿន បានប្រាប់ថា ប្រជាជនដែលបានទៅជាប់នៅក្នុងមន្ទីរសន្តិសុខអូរស្ពាន គឺភាគច្រើនមកពីទីក្រុងភ្នំពេញ ខេត្តុង កំពង់ចាម ស្វាយរៀង និងអ្នក

ដែលបានធ្វើប្រវត្តិរូបថាខ្លួនធ្លាប់បានធ្វើគ្រូបង្រៀន ទាហាន ប៉ូលីស និងថ្នាក់បញ្ញាវន្តដទៃទៀត ។ ចំណែកឯអ្នកមូលដ្ឋានវិញ ឈឹម ខាត់ ជាប្រធានភូមិរលុង បានរៀបរាប់ថាទាល់តែអ្នកនោះមានកំហុសធ្ងន់ដូចជាបានលួចដំឡូង ខ្ជិលច្រអូសនឹងការងារ ធ្លាប់មានបងប្អូនធ្វើទាហានពីសង្គមចាស់ ទើបត្រូវចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខអូរស្វាយដែរ ។ ប្រធានភូមិរូបនោះ បានបង្ហើបប្រាប់ពីឪពុករបស់គាត់ថា បានត្រូវកោះហៅឲ្យទៅកាន់មន្ទីរសន្តិសុខអូរស្វាយដែរដើម្បីអប់រំពីមាគ៌ាបដិវត្ត ប៉ុន្តែរហូតមកដល់ពេលនោះនៅតែគ្មានឃើញឪពុករបស់គាត់ត្រឡប់មកវិញសោះ ។ ខាត់ បានសន្និដ្ឋានតាំងពីថ្ងៃទទួលជ័យជំនះលើខ្មែរក្រហមថា ឪពុករបស់គាត់បានត្រូវសម្លាប់បាត់ហើយនៅនឹងទីតាំងសម្លាប់អូរស្វាយនេះ ។ មិនថាឡើយតែឪពុករបស់ខាត់ទេ ដែលត្រូវបានសម្លាប់នោះ សូម្បីតែអ្នកឯទៀតរាប់រយរាប់ពាន់នាក់ក៏ត្រូវបានសម្លាប់ដូចគ្នាដែរ ។ ការសម្លាប់នេះបានធ្វើឡើងតាំងពីមន្ទីរនេះបានបង្កើតដំបូងនៅឆ្នាំ១៩៧៥ ។ រណ្តៅជាច្រើនបានត្រូវជីកឡើងនៅតាមប្រឡោះដើមឈើទាំងធំទាំងតូចសម្រាប់កប់សាកសពអ្នកទោសដែលបានជាប់នៅអូរស្វាយ ឬធ្លកជ្រុំ ។

ការសម្លាប់មនុស្ស ការចាប់មនុស្សមកឃុំឃាំងនៅទីតាំងមន្ទីរអូរស្វាយនេះ មិនត្រូវបានដឹងដល់មនុស្សភាគច្រើនឡើយ ព្រោះជាផែនការសម្ងាត់របស់ខ្មែរក្រហម ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ រឿងរ៉ាវទាំងអស់បានត្រូវគាស់កកាយឡើងនៅក្រោយបែកឆ្នាំ១៩៧៩ដោយអ្នកឃ្វាលគោ-ក្របី ។ ពីមាត់មួយទៅមាត់មួយបានធ្វើឲ្យទីតាំងនោះលេចព្រុគ្រប់ច្រកល្ហកទាំងអស់ទូទាំងស្រុកទឹកផុស ហើយបានធ្វើឲ្យមានការចាប់អារម្មណ៍បកទៅក្រោយវិញកាលពីធ្លាប់រស់នៅ ធ្លាប់ដឹងខ្លះៗ និងធ្លាប់បានឃើញជាហូរហែរនូវការធ្វើកំណត់ហេតុប្រវត្តិរូបកាលពីជំនាន់ខ្មែរក្រហម រិតតែធ្វើឲ្យការសង្ស័យ និងគិតទុកជាមុននោះក្លាយទៅជាការពិតឥតល្អៀងនូវអ្វីដែលខ្មែរក្រហមបានសាងឡើងក្នុងរយៈកាលនៃការកាន់អំណាចរបស់ពួកគេ ។ ស៊ុំ រឿន ធ្លាប់បានឃើញការដឹកមនុស្សយកចូលក្នុងទីតាំងក្រាំងត្នោត ហើយក្រោយមកគាត់ធ្លាប់បានចូលទៅពិនិត្យដោយផ្ទាល់នៅពេលក្រោយបែកឆ្នាំ១៩៧៩ទៀត ជាហេតុធ្វើឲ្យគាត់ដឹងកាន់តែច្បាស់ថាពិតជាមានការសម្លាប់មនុស្សយ៉ាងពិតប្រាកដមែន ចំណែកឯសៅ ចិន បានដឹងតាំងពីដំបូងថាមានការសម្លាប់មនុស្សនៅក្រាំងត្នោត និងនៅអូរស្វាយ ព្រោះគាត់ធ្លាប់បាននាំចូលទៅកាន់កន្លែងសម្លាប់ពេលដែលព្រឹត្តិការណ៍កំពុងតែកើត ។ នៅនឹងទីតាំងសម្លាប់អូរស្វាយ ឬធ្លកជ្រុំ សៅ ចិន បាននិយាយថាបានឃើញមានរណ្តៅច្រើនណាស់ដែលស្ថិតតែក្នុងប្រវែងប្រហែល២ ឬ ៣ម៉ែត្រពីគ្នាប៉ុណ្ណោះ ។ សៅ ចិន បានត្រូវនាំទៅមើលការសម្លាប់មនុស្សនេះ ប៉ុន្តែត្រូវគាត់វិលត្រឡប់មកកាន់ផ្ទះវិញ ដោយហេតុថាមិនអាចទប់ចិត្តបាន ។ កែ រូន ជានាយរងនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំក្បាលទឹក បានរៀបរាប់ពីការសម្លាប់នេះថា បានបណ្តើរយកទៅសម្លាប់ម្តង៤នាក់ៗរហូតទាល់តែអស់ ។ ចំពោះការសម្លាប់ទាហាន

ដែលជាអតីតទាហានលន់ណុលនោះ គឺមានការកោះប្រជុំជាមុនសិនទើបសម្លាប់ជាក្រោយ ។ ការប្រជុំនោះគឺខ្មែរក្រហមបានរៀបចំពាក្យកុហកបោកប្រាស់ដល់ពួកទាហានទាំងនេះថា មានទាហានលន់ណុលផ្សេងទៀតបានធ្វើឲ្យមានភាពចលាចលក្នុងភូមិស្រុកដែលគេ(ខ្មែរក្រហម)កាន់ក្តាប់ ដូច្នេះពួកគេ(ខ្មែរក្រហម)សុំធ្វើការចងដៃជើងទាហានទាំងអស់ជាបណ្តោះអាសន្នសិនដើម្បីធ្វើការឆែកឆេររកអ្នកដែលបះបោល ។ ក្រោយមកទាហានដែលបានចងដៃជើងនោះ ត្រូវបានយកទៅសម្លាប់ទាំងអស់គ្មានសល់ម្នាក់ឡើយ ។ បន្ទាប់ពីការសម្លាប់ទាហាននេះទៅ មនុស្សដែលជាប្រពន្ធទាហានទាំងនោះ និងកូនក៏បានត្រូវយកទៅសម្លាប់នៅពេលក្រោយដែរ គឺរួមជាមួយនឹងប្រជាជនឯទៀតជាច្រើននាក់ ។ សៅ ចិន ដែលជាអតីតគណៈឃុំក្នុងអំឡុងឆ្នាំ១៩៧០-៧៣នោះបានប្រាប់ពីចំនួនជនរងគ្រោះដែលបានស្លាប់ក្នុងកន្លែងសម្លាប់អូរស្គានថា មានចំនួនមិនតិចជាង១០០០នាក់ឡើយ ។ សៅ ចិន បន្ទាប់ពីផ្លាស់ប្តូរពីគណៈឃុំនៅទួលខ្ពស់ហើយ គាត់បានមកធ្វើជាគណៈឃុំនៅឃុំប្រាំបីមុមស្រុកថ្ពងពីឆ្នាំ១៩៧៥មកដែរ ប៉ុន្តែគាត់ថាបន្ទាប់ពីឆ្នាំ១៩៧៦មកគាត់ត្រូវវិលត្រឡប់ទៅកាន់ឃុំទួលខ្ពស់ស្រុកទឹកផុសវិញ ។

រយៈពេល២៣ឆ្នាំក្រោយមក ស្លាកស្នាមរណ្តៅខ្លះនៃទីតាំងសម្លាប់អូរស្គាន មិនទាន់ត្រូវបានរលប់ទាំងស្រុកឡើយ ។ ខ្ញុំបានថតរូបរណ្តៅនោះដើម្បីទុកជាការបង្ហាញថាជារណ្តៅដ៏ធំដែលបានជីកឡើងដើម្បីសម្លាប់មនុស្សកាលពីជំនាន់ខ្មែរក្រហម ។ រណ្តៅនេះគឺពិតជារណ្តៅដែលបានសម្លាប់មនុស្សដាក់ប្រាកដមែន ដោយមានហេតុផលបញ្ជាក់យ៉ាងច្បាស់ពីសាក្សីបីបួននាក់រួមទាំងបានទៅឃើញផ្ទាល់ និងបង្ហាញដល់ក្រុមខ្ញុំផងថាជារណ្តៅដែលបានកប់សាកសពពិតមែន ។ ក្រៅពីរណ្តៅនេះទៅ ខ្ញុំបានពិនិត្យឃើញមានសំណល់ឆ្អឹងកម្ទេចកំទីខ្លះទៀតដែលមានកាប់នៅក្នុងដីបន្ទាប់ពីខ្ញុំបានកាយដីប៉ែកខាងលើខ្លះមក ។

វត្តមង្គលខាន់ (ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខ)

លេខកូតភូមិសាស្រ្ត ០៨០៨០៧

រយៈកំពស់ **(N) 11º 58' 38:37"**

រយៈទទឹង **(E) 104º 22' 14:93"**

ប្រសិនបើយើងធ្វើដំណើរចេញពីសាលាស្រុកទឹកផុសឆ្ពោះទៅទិសខាងលិចប្រហែល២០គីឡូម៉ែត្រ យើងនឹងទៅដល់ខ្លោងទ្វារវត្តមួយដែលមានឈ្មោះថា វត្តមង្គលខាន់ ។ បច្ចុប្បន្នវត្តនេះ បានត្រូវកំពុងជួសជុល និងស្ថាបនាបន្ថែមនូវសមិទ្ធផលមួយចំនួនទៀតក្រោមការជ្រោមជ្រែងរបស់គណៈកម្មការចំណុះជើងវត្ត និងបង

ប្អូនប្រជារាស្ត្រដែលនិយមធ្វើបុណ្យទាននៅវត្តនេះ ។ ទីធ្លាធំទូលាយគួឲ្យចាប់អារម្មណ៍ ព្រមជាមួយដើមឈើធំៗដែលមានម្លប់ត្រឈឹងត្រឈៃគួរឲ្យចង់សម្រាកពេលថ្ងៃរសៀល ។ រថយន្តរបស់ខ្ញុំបានបញ្ឈប់ក្រោមទិដ្ឋភាពអ៊ូរអរនៃប្រជាជនជាច្រើននាក់ដែលនៅរង់ចាំទទួលរថយន្តមួយផ្សេងទៀតដែលអ្នកទាំងនោះអះអាងថាបានសន្យាមកផ្តល់ទឹកថ្នាំជ្រលក់មុងដើម្បីការពារជម្ងឺគ្រុនចាញ់ ។ ម្នាក់ៗស្ថិតក្នុងសំពាយមុងនៅជាប់នឹងស្មារង់ចាំតែការមកដល់ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំនិងក្រុមទាំងមូលបានសាកសួរនូវទីតាំងប្រល័យពូជសាសន៍ដែលបានកើតមានឡើងនៅក្នុងបរិវេណវត្តមង្គលខាន់នេះ ។ គាំ រី អាយុជាង៣០ឆ្នាំ ជាអតីតទាហានរបស់រដ្ឋកម្ពុជាបានចង្អុលបង្ហាញនូវទីតាំងសម្លាប់មនុស្សនេះ ។ គាត់បានរៀបរាប់ពីហេតុការណ៍នេះថា បានឃើញការសម្លាប់មនុស្សដោយផ្ទាល់ភ្នែកនៅពេលដែលគាត់បានទៅឃ្វាលគោនៅក្បែរទីតាំងសម្លាប់នោះ ។ រីបានពួនមើលយ៉ាងអាថ៌កំបាំង ប៉ុន្តែនៅតែត្រូវចាប់ខ្លួនបានយកទៅសួរចម្លើយ ។ ទីបំផុត រី បានរួចខ្លួនមកវិញដោយសារតែគាត់ជាអ្នកមូលដ្ឋានចាស់ ហើយបានទទួលការព្រមានមិនឲ្យមករវីរវល់នៅក្បែរៗនេះទៀត ។ មានត្រាក់ទ័រចំនួនបីបួនគ្រឿងបានត្រៀមចាំជីករណ្តៅសាកសព និងត្រៀមកៀរសាកសពបញ្ចូលក្នុងរណ្តៅ ។ ការសម្លាប់បានប្រព្រឹត្តិទៅជារៀងរាល់ថ្ងៃ ប៉ុន្តែការសម្លាប់ដែលប្រមូលផ្តុំធំជាងគេគឺនៅក្នុងឆ្នាំ១៩៧៧ ។ ឆ្នាំ១៩៧៥គឺជាកំណើតនៃមន្ទីរសន្តិសុខវត្តមង្គលខាន់ ហើយក៏ជាចំណុចចាប់ផ្តើមនៃការសម្លាប់មនុស្សនៅប៉ែកខាងក្រោយវត្តនេះដែរ ។ ប្រជាជន១៧មេសាជាច្រើនគ្រួសារ បានត្រូវជម្លៀសឲ្យមកស្នាក់នៅត្រឹមវត្តនេះជាបណ្តោះអាសន្ន ។ គ្មានការសួរចម្លើយសម្រាប់ប្រជាជនទាំងនេះទេមុនពេលយកទៅសម្លាប់ចោល ។ ការស្នាក់នៅរបស់ប្រជាជន១៧មេសាគឺស្ថិតនៅក្នុងក្រោមដើមឈើធំៗនៃបរិវេណវត្តមង្គលខាន់ ខ្លះទៀតបានត្រូវយកទៅផ្ញើតាមសហករណ៍និងខ្លះទៀតបានស្នាក់នៅតាមផ្ទះប្រជាជនមូលដ្ឋានចាស់ ។ រី បាននិយាយថាប្រជាជន១៧មេសានេះមានចំនួនប្រហែលរាប់រយគ្រួសារ ។ ប្រជាជនដែលបានជម្លៀសមកពីទីក្រុងភ្នំពេញ, កំពង់ចាម, ស្វាយរៀង និងកន្លែងដទៃទៀតបានត្រូវសម្លាប់ចោលគ្មានសល់នៅឆ្នាំ១៩៧៧ ហើយបន្ទាប់ពីនោះមកវត្តមង្គលខាន់បានទទួលឲ្យស្នាក់នៅចំពោះទាហានដែលត្រូវបានចោទថាបានក្បត់រួមជាមួយមេកើយរបស់ខ្លួនឈ្មោះសោភឹម ។ មេឃាតករចំនួនពីរនាក់បានត្រូវស្គាល់ឈ្មោះម្នាក់ និងម្នាក់ទៀតមិនបានបង្ហើបឲ្យដឹងឈ្មោះឡើយ ។ គាំ រី គ្រាន់តែបានបង្ហាញថា ឃាតកររូបនោះបានសម្លាប់មនុស្សអស់យ៉ាងច្រើននៅវត្តមង្គលខាន់នេះ ហើយរហូតមកដល់បច្ចុប្បន្ននេះនៅមានជីវិតរស់នៅក្នុងភូមិជាមួយគាត់គឺភូមិវត្ត ឃុំទួលខ្ពស់នៅឡើយ ។ មូលហេតុដែល រី មិនហ៊ានបញ្ចេញឈ្មោះឃាតករនោះ ព្រោះខ្លាចក្រែងនៅតែមានការគុំគួនចំពោះគាត់ ។ ចំណែកឯឃាតករម្នាក់ទៀតបានត្រូវប្រាប់ឈ្មោះថា ប៉ាន (សេក ប៉ាន ប្ញង៉ឹត ព្រិល) ។ ប៉ាន មិនមែនជាអ្នកសម្លាប់មនុស្ស ទេ

ប៉ុន្តែគឺជាអ្នកបញ្ជាឲ្យមានការសម្លាប់មនុស្សនៅវត្តមង្គលខាន់នេះ ។ ប៉ាន គឺជាប្រធានកងឈ្លបប្រចាំឃុំទួលខ្ពស់នាសម័យខ្មែរក្រហម ។ បច្ចុប្បន្ន ប៉ាន រស់នៅក្នុងភូមិរកាទង ឃុំទួលខ្ពស់ ស្រុកទឹកផុស ដែលស្ថិតនៅមិនឆ្ងាយប៉ុន្មានពីវត្តមង្គលខាន់នេះឡើយ ។ ខ្ញុំបានទៅជួបគាត់នៅឯខ្ទមដ៏កញ្ចាស់របស់គាត់ដែលរស់នៅតែពីរនាក់នឹងប្រពន្ធរបស់គាត់ ។ ខ្ញុំបានបបួលគាត់មកកាន់វត្តមង្គលខាន់ដែរ ប៉ុន្តែរាល់ចម្លើយរបស់គាត់បានត្រូវបដិសេធនូវគ្រប់សំណួរដែលខ្ញុំបានស្នើ និងបានសួរ ទោះជាក្នុងកិច្ចសម្ភាសន៍ក៏ដោយ ។ រី បានប្រាប់ថាឃាតករសម្លាប់មនុស្សដែលគាត់មិនបានបញ្ចេញឈ្មោះនោះ គឺជាអ្នកទទួលបញ្ជាផ្ទាល់ពី តាប៉ាន នេះតែម្តងក្នុងការសម្លាប់មនុស្ស ។ ប៉ាន គឺជាមនុស្សដែលស្អប់ខ្ពើមជនជាតិចាមខ្លាំងណាស់ ។ នរណាក៏ដោយឲ្យតែស៊ើបទៅដឹងថាមានជនជាតិចាមនៅក្នុងឃុំដែលគាត់កាន់កាប់ គឺត្រូវបានយកទៅសម្លាប់ទាំងអស់ដោយមិនចាំបាច់សួរចម្លើយឡើយ ។ ជាមួយនឹងជីវភាពដុនដាបរបស់គាត់ ប៉ាន បានធ្វើសម្ភាសន៍ជាមួយខ្ញុំនៅក្រោមដើមអំពិលហូបផ្លែមួយដើមក្បែរខ្ទមកំសត់របស់គាត់ទាំងគ្មានអាវពាក់ រួមជាមួយអារម្មណ៍ភ័យខ្លាចជាពន់ពេក ។ ខ្ញុំបានព្យាយាមបញ្ចុះបញ្ចូលនិងពន្យល់ពីសភាពការណ៍បច្ចុប្បន្នដល់គាត់យ៉ាងណាក៏ដោយ ក៏ចម្លើយរបស់គាត់នៅតែខុសពីអ្វីដែលអ្នកស្រុកអ្នកភូមិប្រាប់ខ្ញុំដែរ ។ នៅក្នុងកិច្ចសម្ភាសន៍នេះខ្ញុំសូមលើកយកត្រួសៗនូវអ្វីដែលគាត់បាននិយាយប្រាប់ខ្ញុំទាំងរឿងរ៉ាវសម្លាប់មនុស្សនៅវត្តមង្គលខាន់ផង ។ ប៉ាន គ្រាន់តែជាប្រធានភូមិស្រែចានតែប៉ុណ្ណោះហើយក្រោយមកក៏ត្រូវចាប់ខ្លួនយកទៅដាក់គុកនៅលង្វែកអស់រយៈពេលបីខែ ។ បន្ទាប់ពីចេញពីគុកមក ប៉ាន បានទៅរស់នៅឯស្រុកកំណើតវិញជាមួយប្រពន្ធដែលជាអ្នកដាំបាយនៅក្នុងសហករណ៍ ។ ក្នុងពេលនោះ ប៉ាន មានតួនាទីជាប្រធានភូមិដដែល ហើយមានភារកិច្ចជាអ្នកដឹកនាំប្រជាជនក្នុងភូមិធ្វើស្រែ និងលើកទំនប់...។ ក្នុងពេលនោះហើយដែល ប៉ាន និយាយថាបានឃើញជនរងគ្រោះជាទាហានខ្មែរក្រហមខាងបូព៌ាបានត្រូវបណ្តើរតាមផ្លូវទៅកាន់ជើងភ្នំកញ្ជើបាយដើម្បីសម្លាប់ ។ ចំណែកឯការឃុំឃាំងទាហាននៅក្នុងវត្តមង្គលខាន់វិញ ប៉ាន បានប្រាប់ថាកងឈ្លបបានយកកុដិនានាក្នុងវត្តធ្វើជាកន្លែងឃុំឃាំងនិងធ្វើទារុណកម្មចំពោះទាហានដែលបានចាប់បញ្ជូនមក ។ ប៉ាន គឺជាមនុស្សម្នាក់ដែលមានសិទ្ធិក្នុងការចេញចូលស្រេចចិត្តនៅក្នុងបរិវេណនៃវត្តមង្គលខាន់ ។ ត្រង់ចំណុចនេះហើយដែល ប៉ាន បាននិយាយថាបានឃើញការបណ្តើរទាហានចេញទៅសម្លាប់ចំនួនបីបួនដងព្រមទាំងបាននិយាយទៀតថាពុំដែលមានការសួរចម្លើយ ឬធ្វើទារុណកម្មអ្វីទេ ។ ប៉ាន បានបំពេញតួនាទីរបស់គាត់បានយ៉ាងល្អឥតខ្ចោះតាមបញ្ជាពីថ្នាក់លើ ។ ដល់ថ្ងៃរំដោះឆ្នាំ១៩៧៩ ប៉ាន បានរត់ទៅកាន់តំបន់អន្លង់វែងជាមួយប្រពន្ធ រួមជាមួយនឹងខ្មែរក្រហមឯទៀតដោយសារខ្លាចសេចក្តីស្លាប់ ។ ប៉ាន បាននិយាយទៀតថាក្រោយពីនោះមកគាត់បានស្ម័គ្រចិត្តចូលបម្រើកងទ័ពនៃរដ្ឋកម្ពុជាដើម្បីធ្វើសង្គ្រាមជាមួយខ្មែរក្រហមវិញ ។

ប៉ុន្តែរឿងនេះបានត្រូវបដិសេធដោយ គាំ រី ថាមិនដូច្នេះទេ ព្រោះក្នុងអំឡុងទសវត្សរ៍ទី៨០ និងទី៩០ គាត់បានធ្វើសង្គ្រាមជាមួយកងទ័ពរបស់ ប៉ាន ជាញឹកញាប់ណាស់ ។ ប៉ាន គឺជាមនុស្សដែលស្ថិតនៅក្រោមបញ្ជាការផ្ទាល់ពីតាម៉ុកកាលពីតាម៉ុកមិនទាន់បានចាប់ខ្លួន និងមុនពេលដែលរដ្ឋាភិបាលកម្ពុជាបានធ្វើសមាហរណកម្មជាមួយខ្មែរក្រហម ។ រហូតមកដល់សព្វថ្ងៃនេះ គាំ រី មិនបានដឹងថា ប៉ាន បានមករស់នៅក្នុងភូមិក្បែរៗគាត់ទេ ។

នៅឆ្នាំ១៩៧៨ ទាហានខ្មែរក្រហមខាងភូមិភាគបូព៌ាជាច្រើននាក់បានត្រូវដឹកបញ្ជូនមកកាន់វត្តមង្គលខាន់ដើម្បីទទួលការអប់រំកែប្រែសារជាថ្មី ។ ទាហានទាំងនោះបានក្លាយទៅជាអ្នកទោសយ៉ាងពេញលក្ខណៈនៅក្នុងមន្ទីរសន្តិសុខវត្តមង្គលខាន់ ។ កុដិ ព្រះវិហារ និងកន្លែងឯទៀតបានត្រូវយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលជាទាហានទាំងនោះ ។ ជារឿយៗ រថយន្តធំៗ បានដឹកទាហានព្រមជាមួយនឹងភាពបិទបាំងក្រណាត់កៅស៊ូយ៉ាងជិតចូលមកកាន់វត្តមង្គលខាន់ ហើយដែលក្រោយមករថយន្តនោះបានត្រូវដឹកបញ្ជូនបន្តទៅកាន់ប៉ែកខាងជើងភ្នំកញ្ជើបាយ ។ ប៉ាន បាននិយាយទៀតថា ធ្លាប់បានឃើញការដឹកទាហានបូព៌ានេះទៅកាន់ភ្នំកញ្ជើបាយក្នុងពេលដែលគាត់បានដឹកនាំប្រជាជនធ្វើស្រែ ។ គាំ រីបានឃើញការដឹកនេះដែរនៅពេលដែលគាត់កំពុងឃ្វាលគោឲ្យស៊ីស្មៅ ។ ទាហានខ្លះបានដើរតាមក្រោយរថយន្តក្នុងឯកសណ្ឋានជាទាហានភូមិភាគបូព៌ាចេញទៅ ក្នុងគំនិតទៅច្បាំងជាមួយយួនតាមទល់ដែន ។ ប៉ុន្តែអ្វីៗបានបញ្ចប់ត្រឹមខាងជើងភ្នំកញ្ជើបាយទាំងអស់ ។ ជីវិតទាហានទាំងនោះបានត្រូវសម្លាប់ចោលទាំងអស់ដោយគ្មាននរណាម្នាក់បានរួចខ្លួនពីសេចក្តីស្លាប់ឡើយ ។ ការសម្លាប់នេះបានប្រព្រឹត្តិទៅនៅឆ្នាំ១៩៧៨ ក្រោមការបញ្ជាពីតាម៉ុក និង យាយម៉ែនដែលជាថ្នាក់លើ ។ ប៉ាន បាននិយាយដូច្នេះទៀតថា មិនដែលបានឃើញមុខតាម៉ុក ឬយាយម៉ែនទេ ប៉ុន្តែបានទទួលតែបញ្ជាប៉ុណ្ណោះ ។ ការឃុំឃាំង និងសម្លាប់មនុស្សនៅវត្តមង្គលខាន់បានត្រូវបញ្ចប់នៅត្រឹមថ្ងៃរំដោះឆ្នាំ១៩៧៩ ជាមួយសំណល់ខ្ទោះ និងវត្ថុតាងផ្សេងៗទៀតដែលបច្ចុប្បន្នត្រូវវិនាសអស់ទៅហើយ ។ មានរណ្តៅចំនួនពីរបីបានបន្សល់នូវស្លាកស្នាមខ្លះៗនៅប៉ែកខាងក្រោយវត្តមង្គលខាន់ ។ រណ្តៅទាំងនោះមានទំហំធំគឺប្រហែលជាទទឹង៥ម៉ែត្រ និងបណ្តោយពី៨ទៅ១០ម៉ែត្រ ។ គាំ រី បានបន្ថែមថាមានរណ្តៅច្រើនណាស់ ប៉ុន្តែត្រូវបានលុបវិញអស់ហើយបន្ទាប់ពីមានការជីករកមាសពីប្រជាជនមក ។ ចំណែកឯជនរងគ្រោះដែលបានស្លាប់វិញ គាំ រី មិនហ៊ានសន្និដ្ឋានទេ ប៉ុន្តែគាត់បាននិយាយថាមានរាប់រយគ្រួសារនៃប្រជាជន១៧មេសាដែលបានមកស្លាប់ទីនេះ ។ ប្រជាជនមូលដ្ឋានចាស់ មិនត្រូវបានសម្លាប់នរណាម្នាក់ឡើយ ព្រោះជាមនុស្សដែលអង្គការចាត់ទុកថាធ្លាប់មានការកំសត់កម្រ ។

*ភ្នំអន្ទ (ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខ)*

*លេខកូតភូមិសាស្ត្រ ០៨០៨០៨*

*រយៈកំពស់* **(N) 12º 02' 03:68"**

*រយៈទទឹង* **(E) 104º 30' 27:34"**

*មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មួយបានត្រូវបង្កើតឡើងនៅចន្លោះភ្នំពីរគឺភ្នំអន្ទ និងភ្នំតូច ។ ភ្នំទាំងពីរនេះស្ថិតនៅមិនឆ្ងាយពីគ្នាប៉ុន្មានទេ ។ កាលពីជំនាន់ដែលគ្រប់គ្រងដោយរបបខ្មែរក្រហម ព្រៃឈើធំៗបានត្រូវកាប់រំលំខ្ទេចខ្ទីអស់ដើម្បីយកទីធ្លានោះធ្វើស្រែចម្ការ ។ ចំណែកឯជើងភ្នំអន្ទបានត្រូវកសាងជាមន្ទីរសន្តិសុខមួយឡើងដើម្បីឃុំឃាំងជនរងគ្រោះដែលមានកំហុស ។ មន្ទីរសន្តិសុខភ្នំអន្ទ គឺជាមន្ទីរមួយដែលមានកំរិតឃុំឃាំងធ្ងន់ធ្ងរជាងគេក្នុងចំណោមមន្ទីរឃុំឃាំងពីទៀតគឺវិទ្យាល័យទឹកផុស និងភ្នំកញ្ជាំងដែលមានជាប់តែអ្នកទោសស្ត្រី ។ នៅឆ្នាំ១៩៧៧ មន្ទីរសន្តិសុខនេះបានលេចមុខមាត់ឡើងយ៉ាងល្បីរន្ទឺពេញស្រុកទឹកផុសថាជាមន្ទីរឃុំឃាំងដែលមានវិន័យតឹងរ៉ឹងបំផុត ។ ចំពោះអ្នកទោសគឺតម្រូវឲ្យដាក់ខ្នោះជាប្រចាំទោះជាអ្នកទោសប្រភេទធ្ងន់ឬស្រាលក៏ដោយ ។ ពេលបន្ទោរបង់ម្តងៗអ្នកទោសត្រូវបានដោះខ្នោះចេញ ហើយចូលខ្នោះដោយខ្លួនឯងវិញនៅពេលការបន្ទោរបង់នេះរួចរាល់ហើយ ។ យ៉ុនបាននិយាយប្រាប់ថា ប្រសិនបើមានអ្នកទោសណាម្នាក់ហ៊ានរត់ចេញពីគុកតែម្នាក់ គឺត្រូវសម្លាប់ចោលទាំងអស់ចំពោះអ្នកទោសផ្សេងទៀត ។ ក្នុងមនោសញ្ចេតនាអាណិតគ្នាទៅវិញទៅមក យ៉ុន បានប្រាប់ថាគ្មានអ្នកទោសណាម្នាក់ហ៊ានធ្វើដូច្នេះឡើយ ។ អ្នកទោសបានត្រូវបែងចែករវាងបុរសនិងស្ត្រីក្នុងការសម្រាកពេលយប់ ។ ការងារត្រូវបានបណ្តើរឲ្យធ្វើការដោយពុំមានដាក់ខ្នោះអ្វីឡើយ ប៉ុន្តែនៅពេលយប់អ្នកទោសទាំងអស់ត្រូវរុញបញ្ចូលខ្នោះឈើដោយពុំមាននរណារួចខ្លួនឡើយ ។ ការងាររបស់អ្នកទោសគឺគ្មានអ្វីក្រៅពីធ្វើស្រែ ដាំដូឡុង ធ្វើព្រៃខាងជើងភ្នំអន្ទ ។ល ។ ហេង យ៉ុន គឺជាអ្នកទោសដែលបានជាប់នៅមន្ទីរសន្តិសុខភ្នំអន្ទអស់រយៈពេល៩ខែ ។ យ៉ុន មានអាយុ៤៤ឆ្នាំនៅក្នុងឆ្នាំនេះ(២០០២) ។ យ៉ុនជាប់គុកដោយសារតែមានប្តីជាកម្មាភិបាលខ្មែរក្រហមដែលបានក្បត់នឹងអង្គការ ហើយបន្ទាប់ត្រូវអង្គការចាប់ខ្លួនយកមកឃុំឃាំងនិងធ្វើទារុណកម្មរហូតដល់ស្លាប់ ។ ឈ្មោះ ណុន គឺជាប្តីរបស់គាត់(យ៉ុន) ។ ណុន គឺជាអតីតប្រធានឃុំខ្ទុងពពក ស្រុកទឹកផុសក្នុងអំឡុងឆ្នាំ១៩៧៥-៧៦ ។ ណុន ត្រូវបានចាប់ខ្លួនដោយសមាជិកកងឈ្លបឃុំខ្ទុងពពកយកទៅដាក់គុក នៅពេលដែលប្រពន្ធរបស់គាត់(យ៉ុន)កំពុងឆ្លងទន្លេនៅមន្ទីរពេទ្យឃុំដដែលនេះ ។ យ៉ុនមិនបានដឹងពីការចាប់ខ្លួនប្តីរបស់គាត់ឡើយ ។ លុះរយៈពេល១០ថ្ងៃក្រោយការឆ្លងទន្លេ យ៉ុន ក៏ត្រូវចាប់*

ខ្លួនដែរ ។ ដំបូង យ៉ុន ត្រូវនាំយកទៅដាក់នៅមន្ទីរសន្តិសុខនៅភ្នំកញ្ច្រៀង ។ យ៉ុន រស់ នៅក្នុងមន្ទីរនោះអស់រយៈពេលមួយខែ បន្ទាប់មកត្រូវបញ្ជូនបន្តមកដាក់នៅមន្ទីរសន្តិសុខនៃវិទ្យាល័យទឹកផុស ។ នៅទីនោះ យ៉ុន បានជាប់អស់រយៈពេលជាង៦ខែទៀត ។ ពេលដែលគាត់បានមកដល់វិទ្យាល័យទឹកផុស គឺចំពេលដែលប្តីរបស់គាត់បានត្រូវផ្លាស់ប្តូរមកដាក់មន្ទីរឃុំឃាំងនៅភ្នំអន្គ ។ ទីនោះហើយដែលប្តីរបស់ យ៉ុន បានត្រូវសម្លាប់ ។ ចំណែកឯ យ៉ុន វិញក៏ត្រូវបញ្ជូនមកកាន់មន្ទីរសន្តិសុខភ្នំអន្គដែរបន្ទាប់ពីប្តីត្រូវបានសម្លាប់ ។ កូន របស់ យ៉ុន ដែលមានអាយុមិនទាន់១ឆ្នាំផងបានត្រូវយកទៅចិញ្ចឹមដោយពេទ្យឃុំហើយសព្វថ្ងៃនេះនៅមានជីវិតនៅឡើយ ។

ការចាប់ខ្លួនរបស់យ៉ុននិងប្តីរបស់គាត់គឺស្ថិតនៅក្នុងអំឡុងឆ្នាំ១៩៧៧ ។ យ៉ុន បានត្រូវធ្វើទណ្ឌកម្មយ៉ាងសាហាវបំផុតពីខ្មែរក្រហមដែលនៅកាន់កាប់មន្ទីរសន្តិសុខភ្នំអន្គ ។ យ៉ុន បានប្រាប់ថាគ្មានអ្នកទោសណាម្នាក់បានគេចផុតពីការធ្វើទារុណកម្មឡើយ ។ មានរោងជាច្រើនបានសង់យ៉ាងប្រជ្រៀតគ្នា ហើយដែលរោងនិមួយៗមានបណ្តោយប្រហែល១០ម៉ែត្រ និងទទឹង៥ម៉ែត្រ ។ រោងមួយៗមានអ្នកទោសជាង១០០នាក់ស្នាក់នៅ ។ ក្នុងរយៈពេលជាងចំនួន៩ខែនៃជីវិតរបស់ យ៉ុន ក្នុងមន្ទីរឃុំឃាំងភ្នំអន្គ គាត់បានភ្ញាក់រស់ជាតិនូវកិច្ចការពិបាកៗជាច្រើនដំពូក ។ អ្នកទោសប្រភេទធ្ងន់ៗ បន្ទាប់ពីធ្វើទណ្ឌកម្មហើយបានត្រូវទុកចោលរហូតដល់ស្លាប់ និងជួនកាលបានត្រូវអូសយកទៅបង្ហើយ(សម្លាប់) នៅក្នុងរណ្តៅជាច្រើនដែលមានចម្ងាយប្រហែលតែពី ២០ទៅ៣០ម៉ែត្រពីរោងនៃមន្ទីរឃុំឃាំងនោះ ។ អ្នកទោសថ្មីៗជាច្រើន បានត្រូវបញ្ជូនចូលមកជាហូរហែរ ។ ឯការសួរចម្លើយក៏មានកើតឡើងជាហូរហែរដែរ ។ យ៉ុន ធ្លាប់បានឮសូរសម្លេងស្រែកឡូឡានៅពេលសួរចម្លើយម្តងៗ ។

យ៉ុន បានបន្ថែមទៀតថាមានរណ្តៅច្រើនរាប់មិនអស់នៅខាងជើងភ្នំអន្គ ប៉ុន្តែសព្វថ្ងៃត្រូវរលាយអស់ហើយដោយសារតែការរានដីធ្វើស្រែរបស់ប្រជាជន ។ មានជនរងគ្រោះជាច្រើននាក់បានត្រូវសម្លាប់ និងស្លាប់ដោយជម្ងឺហើម និងការធ្វើទណ្ឌកម្ម ។ យ៉ុន បាននិយាយថា មន្ទីរសន្តិសុខភ្នំអន្គគឺជាកន្លែងលត់ដំធ្ងន់ធ្ងរទី១នៅទូរទាំងស្រុកទឹកផុស ។ ភាគច្រើននៃអ្នកទោសគឺជាកម្មាភិបាលរបស់ខ្មែរក្រហមហើយដែលក្រោយមកបានត្រូវកម្ទេចចោលទាំងអស់ ។ យ៉ុន បានស្គាល់ឈ្មោះអ្នកវ៉ៃសម្លាប់មនុស្សនៅភ្នំអន្គ ហើយបាននៅរស់រហូតដល់សព្វថ្ងៃនេះគឺស្ថិតនៅខាងក្រោយវត្តខ្ទុងពពក ។ ជនដៃដល់រូបនោះមានឈ្មោះ គន់ ។ គន់ នេះក៏ធ្លាប់បានវាយធ្វើបាប យ៉ុន ដែរព្រោះតែសណ្តែកលីងមួយកំប៉ុង ។ ប៉ុន្តែការធ្វើរបៀបនេះ យ៉ុន និយាយថាគឺជាការព្រមានប៉ុណ្ណោះសម្រាប់គាត់ ។ នៅចុងឆ្នាំ១៩៧៨ ស្ថានភាពនយោបាយបានត្រូវរង្គោះរង្គើ ។ ក្រុមនារីៗជាង២០នាក់ដែលក្នុងនេះមាន យ៉ុន ដែរបានត្រូវដោះលែងឲ្យរួចខ្លួនវិញ ។ អ្នកទោសប្រុសៗ ត្រូវបានសម្លាប់យ៉ាងតក់ក្រហល់នៅចុងឆ្នាំ១៩៧៨មុនពេលដែលថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩បានចូលមកដល់ ។ មន្ទីរសន្តិសុខ

*ភ្នំអន្តង់ទាំងមូលបានត្រូវដុតបំផ្លាញនិងរុះរើខ្ទេចអស់ ។ សំណល់ភស្តុតាងអ្វីបន្តិចក៏គ្មានបានបន្សល់ទុកដែរ មានតែការពិតប៉ុណ្ណោះដែលអាចបញ្ជាក់យ៉ាងច្បាស់លាស់បាន ហើយដែលការពិតនេះត្រូវតែចេញដោយផ្ទាល់មាត់ពីជនរងគ្រោះដែលធ្លាប់បានឆ្លងកាត់ផ្ទាល់កាលពីជំនាន់ខ្មែរក្រហមប្រាប់តគ្នាពីម្តាយទៅកូន ឬពីម្នាក់ទៅម្នាក់ ។ យ៉ុន បានផ្តើមនិយាយរឿងរ៉ាវរបស់គាត់ប្រាប់ទៅកូនរបស់គាត់តាំងពីកូនគាត់នៅរៀនសាលាបឋមសិក្សាម៉្លេះ ប៉ុន្តែហាក់ដូចជាគ្មានការជឿទុកចិត្តចំពោះការនិយាយនេះទាល់តែសោះ ។ រហូតមកដល់សព្វថ្ងៃនេះ ក៏គាត់នៅតែនិយាយជារឿយៗនូវប្រវត្តិជីវិតពិតរបស់គាត់ដែលបានហែលឆ្លងកាត់គ្រប់ឧបសគ្គទាំងអស់ ទើបអាចមានជីវិតរស់នៅដល់សព្វថ្ងៃនេះបាន ។ យ៉ុន មានផ្ទះស្ថិតនៅក្នុងព្រៃដាច់ឆ្ងាយពីគេឯង ព្រោះគាត់មានប្តីក្រោយមួយទៀតជាអតីតទាហានខ្មែរក្រហមដែលបោះបង់ការតស៊ូរបោលតាំងពីថ្ងៃរំដោះឆ្នាំ១៩៧៩ ។ កំពូលភ្នំអន្តង់ គឺជាកំពូលភ្នំទី១ដែល យ៉ុន បានមើលឃើញព្រឹកល្ងាចនាបច្ចុប្បន្ននេះ ។ យ៉ុន និយាយថាពេលក្រឡេកមើលឃើញកំពូលភ្នំនេះ ធ្វើឲ្យគាត់នឹកឃើញទាំងអស់នូវអ្វីដែលបានកើតឡើងចំពោះគាត់កាលពីសម័យខ្មែរក្រហម ។*

***វិទ្យាល័យទឹកផុស (ទីតាំងសម្លាប់ និង មន្ទីរសន្តិសុខ)***

***លេខកូតភូមិសាស្ត្រ ០៨០៨០៩***

***រយៈកំពស់* (N) 12º 03' 25:43"**

***រយៈទទឹង* (E) 104º 31' 40:22"**

*វិទ្យាល័យទឹកផុស គឺជាកំរិតធ្ងន់ទី២នៃមន្ទីរសន្តិសុខរបស់ខ្មែរក្រហមនៅស្រុកទឹកផុស ។ មន្ទីរនេះបានត្រូវបង្កើតឡើងនៅឆ្នាំ១៩៧៥ គឺភ្លាមៗបន្ទាប់ពីការទទួលបានជ័យជំនះលើចក្រពត្តិរបស់ខ្មែរក្រហម ។ ការបង្កើតគុកនេះឡើងគឺសម្រាប់ឃុំឃាំងអ្នកទោសដែលបានប្រព្រឹត្តិខុសនឹងបញ្ជារបស់អង្គការ, ប្រជាជន១៧ មេសា និងអ្នកដែលមានជាប់ពាក់ពន្ធ័និន្នាការនយោបាយផ្សេងៗ ។ ចំណែកទាហាន គឺជាគោលដៅដំបូងបង្អស់របស់ខ្មែរក្រហមនៃការចាប់ខ្លួននេះ ។ ជនរងគ្រោះបានត្រូវបណ្តើរទាំងខ្សែៗមកដាក់នៅក្នុងបរិវេណវិទ្យាល័យនេះ ហើយក្រោយមកត្រូវបានសម្លាប់ទាំងអស់ក្នុងអំឡុងឆ្នាំ១៩៧៥ដែរ ។ ហេង យ៉ុន បានឃើញការបណ្តើរនេះដោយផ្ទាល់នឹងភ្នែកថាមានចងស្លាបសេក និងបណ្តើរជាខ្សែនូវមនុស្សយ៉ាងច្រើនចូលទៅក្នុងវិទ្យាល័យនេះ ។ មានអ្នកទោសប្រហែលពី៣០ទៅ៤០នាក់ត្រូវបាន យ៉ុន មើលឃើញនឹងភ្នែកថាបានត្រូវសម្លាប់ដោយកងឈ្លបខ្មែរក្រហមទម្លាក់ចូលក្នុងរណ្តៅខ្លះ និងវាយប៉ាយខ្លះ ។ យ៉ុន បាននិយាយទៀតថាមានអ្នកទោសទាំងស្រីទាំងប្រុសស្នាក់នៅយ៉ាងអ៊ូរអរពេញទីធ្លាវិទ្យាល័យនេះ ។ ប៉ុន្តែមួយរយៈក្រោយមកអ្នកទោសដែលជា*

បុរសបានត្រូវនាំយកទៅសម្លាប់ ។ ការសម្លាប់មនុស្សនៅវិទ្យាល័យទឹកជុស បានប្រព្រឹត្តិទៅរហូតដល់ឆ្នាំ ១៩៧៧ ទើបត្រូវបញ្ឈប់ ។ ការបញ្ឈប់នេះគឺដោយសារតែមានការផ្លាស់ប្តូរ ទីកន្លែងទៅកាន់ភ្នំអង្គរវិញ ។ យ៉ុន គឺជាអ្នកទោសម្នាក់ដែលមានតួនាទីជាអ្នកដាំបាយឲ្យអ្នកទោសជាមួយនារី ៗ ប៉ុន្មាននាក់ទៀតក្នុងខែដំបូងនៃ ការជាប់ទោស ។ លុះបន្ទាប់ពីនោះមកយ៉ុនបានប្តូរទៅជាអ្នកកាប់ដី គាស់ដីដំបូក និងកាប់ឆ្ការព្រៃវិញ ។ ពេលកាប់ឆ្ការព្រៃនេះហើយដែលយ៉ុនបានឃើញការសម្លាប់មនុស្សមួយបានកើតមានឡើងនៅដើមឆ្នាំ១៩៧៧ មុនពេលមានការផ្លាស់ប្តូរទីកន្លែង ។ ដោយសារតែមានគ្រួសារជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទថាក្បត់ទើប យ៉ុន ព្រមទាំងឪពុកម្តាយក្មេងត្រូវជាប់ឃុំឃាំងបែបនេះ ។ ឪពុក ម្តាយក្មេងរបស់គាត់បានត្រូវសម្លាប់ តែក្នុងរយៈពេលខ្លីនៃការឃុំខ្លួននៅមន្ទីរឃុំឃាំងនៃវិទ្យាល័យទឹកជុស ។

មានរណ្តៅសាកសពជាង១០០ដែលស្ថិតនៅប៉ែកខាងក្រោយវិទ្យាល័យទឹកជុស ហើយដែលរណ្តៅនិមួយ ៗ អាចផ្ទុកសាកសពបានពី៥ ទៅ៦ នាក់ ។ ដូច្នេះតាមការប៉ាន់ស្មាននេះ ចំនួនសាកសពសរុបទាំងអស់មានចំនួនពី៥០០ទៅ៦០០នាក់ ។ ក្រោយឆ្នាំ១៩៧៧ វិទ្យាល័យនេះនៅតែមានឈ្មោះជាមន្ទីរឃុំឃាំងដដែល ប៉ុន្តែពុំមានអ្នកទោសទៀតទេ ព្រោះត្រូវផ្ទេរទៅកាន់មន្ទីរសន្តិសុខនៅភ្នំអង្គអស់ហើយ ។